# មជ្ឈមណ្ឌលដើម្បីសន្តិភាព និង អភិវឌ្ឍន៍

# វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

Centre for Peace and Development (CPD)
Cambodia Development Resource Institute (CDRI)

## កំណត់ហេតុកិច្ចប្រជុំខប់សែលខមលើកទី ៩

## យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ដំណាក់កាលទី ២

## ថ្ងៃព្រហស្បតិ៍ ទី២៥ ខែឧសភា ឆ្នាំ ២០០៦

## វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**ខប់សែល ដំណាក់កាលទី ២**
**COPCEL Phase II**

*ឧបត្ថម្ភដោយ / Sponsored by*

**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**
**United Nations Development Programme (UNDP)**

## របៀបវារៈនៃកិច្ចប្រជុំ

១. ការពិនិត្យនិងអនុម័តនូវកំណត់ហេតុកិច្ចប្រជុំខប់សែលខមលើកទី៨ និងកំណត់ហេតុកិច្ចប្រជុំខប់សែលឡឹមលើកទី ៣

២. ការចែករំលែកព័ត៌មានទូទៅជុំវិញការរៀបចំការបោះឆ្នោត-ការបង្ហាញពីរបាយការណ៍ស្តីអំពី ដំណើរបេសកកម្មទៅខេត្តកោះកុងដើម្បីសាកសួរព័ត៌មានសំរាប់រៀបចំកិច្ចប្រជុំខប់សែលនៅថ្នាក់ខេត្ត នៅខេត្តកោះកុងកាលពីថ្ងៃទី១៩ ខែឧសភា

៣. កិច្ចពិភាក្សាអំពីសកម្មភាពចែកអំណោយ និង សកម្មភាពផ្សេងៗរបស់គណបក្សនយោបាយក្នុងពេលយុទ្ធនាការឃោសនាបោះឆ្នោត

៤. សេចក្តីផ្សេងៗ

## ១. ការពិនិត្យនិងអនុម័តនូវកំណត់ហេតុកិច្ចប្រជុំខប់សែលខមលើកទី៨ និងកំណត់ហេតុកិច្ចប្រជុំខប់សែលឡឹមលើកទី ៣

លោក **ឱក សេរី សោភ័ក្តិ** ទីប្រឹក្សានៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (*វបសអ*) និងជាអ្នកសំរបសំរួលកិច្ចប្រជុំខប់សែលបានស្វាគមន៍ដល់សមាជិកអង្គប្រជុំ ដែលបានចំណាយពេលដ៏មានតម្លៃអញ្ជើញចូលរួមក្នុងកិច្ចប្រជុំខប់សែលខមលើកទី៩ នៃយន្តការខប់សែលដំណាក់កាលទី ២ នេះ ។ លោកបានស្នើយោបល់អង្គប្រជុំលើរបៀបវារៈកិច្ចប្រជុំ ខប់សែលខមលើកទី ៩ និងការអនុម័តកំណត់ហេតុកិច្ចប្រជុំខប់សែលខមលើកទី ៨ និងកំណត់ហេតុកិច្ចប្រជុំខប់សែលឡឹមលើកទី ៣ ។ លោកបានបញ្ជាក់ថាការអនុម័តកំណត់ហេតុទាំងពីរនេះ ដើម្បីឆ្លើយតបទៅនឹងខ្លឹមសារនៃកំណត់ហេតុទាំងពីរនេះ ក្នុងគោលបំណងឱ្យសមស្របពេលវេលាដែលរដ្ឋសភាកំពុងត្រៀមរៀបចំអនុម័តច្បាប់បោះឆ្នោតឃុំ-សង្កាត់ខាងមុខនេះ ។ អង្គប្រជុំបានអនុម័តកំណត់ហេតុកិច្ចប្រជុំខប់សែលខមលើកទី ៨ និងកំណត់ហេតុកិច្ចប្រជុំខប់សែលឡឹមលើកទី ៣ យកជាផ្លូវការ ។

## ២.ការចែករំលែកព័ត៌មានទូទៅជុំវិញការរៀបចំការបោះឆ្នោត-ការបង្ហាញពីរបាយការណ៍ស្តីអំពីដំណើរបេសកកម្មទៅខេត្តកោះកុងដើម្បីសាកសួរព័ត៌មានសំរាប់រៀបចំកិច្ចប្រជុំខប់សែលនៅថ្នាក់ខេត្ត នៅខេត្តកោះកុងកាលពីថ្ងៃទី ១៩ ខែឧសភាឆ្នាំ ២០០៦

លោក **ឱក សេរី សោភ័ក្តិ** បានលើកឡើងថាដោយមានសំណើពី UNDP និងជិតដល់ពេលវេលារៀបចំការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ កិច្ចប្រជុំខប់សែលខម និងខប់សែលឡឹមគួរនឹងធ្វើបញ្ចូលគ្នានៅភ្នំពេញបើមានការយល់ព្រមពីអង្គប្រជុំដើម្បីធានា ឱ្យមានការចូលរួមបានទូលំទូលាយពីគ្រប់ភាគីពាក់ព័ន្ធ ។ លោកបានជំរាបជូនអង្គប្រជុំអំពីដំណើរបេសកកម្មរបស់ក្រុមខប់សែលទៅកាន់ខេត្តកោះកុង ដើម្បីសិក្សាអំពីស្ថានការណ៍ជាក់ស្តែងនៅទីនោះទាក់ទងនឹងការបោះឆ្នោត មុននឹងរៀបចំកិច្ចប្រជុំផ្ទាល់នៅខែកក្កដា ឆ្នាំ ២០០៦ ។ នៅក្នុងដំណើរបេសកកម្មនេះ ក្រុមខប់សែល ត្រូវបានទទួលការស្វាគមន៍យ៉ាងកក់ក្តៅពីសំណាក់ឯកឧត្តម **យុទ្ធ ភូថង** អភិបាលខេត្តកោះកុង និងទទួលបានការគាំទ្រយ៉ាងខ្លាំងពីសំណាក់អាជ្ញាធរខេត្ត មានឯកឧត្តមអភិបាលខេត្តកោះកុង លោកប្រធាន PEC ខេត្ត និងសង្គមស៊ីវិល ក្នុងការរៀបចំកិច្ចប្រជុំខប់សែលប្រ៉មនៅថ្នាក់ខេត្តនេះ ។ ក្រុមខប់សែលបានទទួលព័ត៌មានមួយចំនួនជាពិសេសបញ្ហាចុះឈ្មោះបោះឆ្នោតគឺជួបការលំបាកខ្លាំងព្រោះភូមិសាស្ត្រជាកោះត្រូវប្រើកាណូតច្រើនផ្លូវក៏លំបាក ។ សមត្ថភាព មានតែមធ្យោបាយមិនមាន ។ ខប់សែល កំពុងតែទាក់ទងជាមួយនឹងអង្គការនានាដែលមានប្រតិបត្តិការនៅទីនោះហើយ UNDP ក៏បានដឹង

ដែរនៅក្នុងរឿងនេះបើអាចជួយដល់ PEC និងដល់ក្រុមប្រឹក្សាឃុំសង្កាត់ខេត្តកោះកុង ព្រោះមិនមានលទ្ធភាពនឹងគ្របដណ្តប់ឱ្យបានគ្រប់ប្រជាពលរដ្ឋដែលនៅតាមកោះតាមទីកន្លែងឆ្ងាយៗ។

ខប់សែលមានមោទនភាពដោយនៅក្នុងរយៈពេល ២ ខែកន្លងមកនេះនៅតាមទូរទស្សន៍ តាមកាសែតក្តី ឃើញមានយុទ្ធនាការផ្តល់អត្តសញ្ញាណប័ណ្ណជាតិខ្មែរដល់ប្រជាពលរដ្ឋយ៉ាងខ្លាំងនៅគ្រប់ខេត្តក្រុង ពិសេសទាំងក្រសួងមហាផ្ទៃនិងនគរបាលជាតិ។ ខប់សែលសង្ឃឹមថាក្នុងឆ្នាំ ២០០៦ យុទ្ធនាការនេះបើមិនបានដល់ ១០០ ភាគរយ ក៏អាចនឹងបានទទួលនូវលទ្ធផលគួរជាទីពេញចិត្តដែរ ហើយលោកក៏បានថ្លែងអំណរគុណយ៉ាងខ្លាំងដល់តំណាងរបស់ក្រសួងមហាផ្ទៃ និងជាសមាជិករបស់ខប់សែលដែលបានធ្វើការសំរបសំរួល និងបញ្ជូនព័ត៌មានដែលខប់សែលបានលើកឡើងទៅថ្នាក់ដឹកនាំផ្ទាល់ដើម្បីចាត់វិធានការទាន់ពេលវេលា ។

ឯកឧត្តម **ទេព នីថា** អគ្គលេខាធិការ គជប បានជម្រាបនូវព័ត៌មានមួយចំនួនទាក់ទងនឹងសកម្មភាពរបស់ គជប ជាពិសេសក្នុងការត្រៀមរៀបចំការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ ។ នៅគណៈកម្មការអចិន្ត្រៃយ៍របស់រដ្ឋសភាបានប្រជុំ ដើម្បីឆ្លងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ។ សម្រាប់ការត្រៀមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ ២០០៧ គជប បានធ្វើគម្រោងថវិកាប៉ាន់ស្មាន ១៣.០៥០.០០០ ដុល្លា គម្រោងថវិកានេះបានដាក់ជូនរាជរដ្ឋាភិបាល និងបានចារទៅក្រសួងហិរញ្ញវត្ថុ គជប បានជួបប្រជុំជាមួយអន្តរក្រសួងទាក់ទងនឹងថវិកានេះ ហើយបានឯកភាពជាគោលការណ៍ស្នើទៅនាយករដ្ឋមន្ត្រីលើគម្រោងថវិកា ។ ការសម្រេចយ៉ាងណានោះប្រហែលជាត្រូវរង់ចាំនៅពេលច្បាប់បោះឆ្នោតចូលជាធរមាន ។ គម្រោងនេះបើប្រៀបធៀបការចំណាយទៅនឹងការបោះឆ្នោតមុនៗអាចមានច្រើនការបោះឆ្នោតតំណាងរាស្ត្រឆ្នាំ ២០០៣ ព្រោះការចំណាយការបោះឆ្នោតឆ្នាំ ២០០៣ សម្រាប់មនុស្សម្នាក់ៗ មានជាង ១ ដុល្លា ឥឡូវនេះជិត ២ ដុល្លាម្នាក់ សម្រាប់ថវិកា ១៣ លានជាងនេះ ។ តាមគម្រោងថវិកានេះ គជប ប៉ាន់ស្មានអ្នកបោះឆ្នោតជិត ៧ លាននាក់ព្រោះឥឡូវនេះឈ្មោះអ្នកមានក្នុងបញ្ជីបោះឆ្នោត ៦ លាន ៧ សែននាក់ហើយដោយការចុះឈ្មោះឆ្នាំនេះជាឆ្នាំបោះឆ្នោតទៀត អ្នកបោះឆ្នោតអាចឡើង ៣០ ម៉ឺននាក់ ព្រោះការចុះឈ្មោះប្រចាំឆ្នាំកន្លងមកឆ្នាំ ២០០៤ ២០០៥ ក្នុងមួយឆ្នាំៗមានអ្នកចុះឈ្មោះក្រោម ២៥ ម៉ឺននាក់ ។

ថ្មីៗនេះអគ្គលេខាធិការដ្ឋាន គជប បានប្រជុំពិនិត្យប្រតិទិនសម្រាប់ការបោះឆ្នោតដោយផ្អែកលើសេចក្តីព្រាងច្បាប់ដែលដាក់ឆ្លងទៅសភានេះ ដោយបានពិនិត្យលើប្រតិទិននេះ ហើយនឹងដាក់ជូន គជប ពិនិត្យសម្រេចនៅក្រោយដែលច្បាប់ចេញជាធរមាន ។ ប្រតិទិននិងផែនការមេសម្រាប់ការបោះឆ្នោតនេះដែលរៀបចំតាំងពីការចុះឈ្មោះរហូតដល់ចប់ការបោះឆ្នោត ហើយផែនការមេនេះក៏ត្រូវបានពិនិត្យដែរដោយផ្អែកទៅលើសេចក្តីព្រាងច្បាប់ ។ គជប បានសាកល្បងធ្វើការចែកប័ណ្ណព័ត៌មានដល់អ្នកបោះឆ្នោតនៅក្នុងឃុំ ១០ នៃខេត្ត ១០ ហើយបានទទួលលទ្ធផលតែ ៦៤ ភាគរយ ដែលនេះគឺជាលទ្ធផលល្អ ។ ការងារនេះគោលបំណងដំបូង គឺជូនព័ត៌មានអ្នកបោះឆ្នោតឱ្យបានទូលំទូលាយ ព្រោះការបោះឆ្នោតកន្លងមកអ្នកបោះឆ្នោតមានតែ ៨៧ ភាគរយ ។ ក្រសួងមហាផ្ទៃកំពុងជំរុញឱ្យចេញអត្តសញ្ញាណប័ណ្ណដើម្បីប្រើប្រាស់នៅពេលបោះឆ្នោត ។ មានបញ្ហាពី ករណីឈ្មោះក្នុងអត្តសញ្ញាណប័ណ្ណ និងឈ្មោះក្នុងបញ្ជីបោះឆ្នោតមិនត្រូវគ្នា ។ គជប បានណែនាំឱ្យគណៈកម្មាធិការខេត្តរៀបចំការបោះឆ្នោតបច្ចុប្បន្ននេះ ធ្វើការជាមួយអាជ្ញាធរឃុំសង្កាត់ដើម្បីពិនិត្យលើបញ្ហានេះ:

ទី១. សូមឱ្យគាត់បញ្ជាក់ឯកសាររបស់គាត់ឡើងវិញ ដើម្បីដូរឈ្មោះគាត់នៅក្នុងបញ្ជីបោះឆ្នោតនៅពេលចុះឈ្មោះឆ្នាំនេះសម្រាប់ការបោះឆ្នោតឃុំសង្កាត់ ដូរឈ្មោះគាត់ឱ្យត្រូវតាមកាតរបស់គាត់។

ទី២. ក្នុងករណីពុំមានអត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋ គជប នឹងចេញទំរង់ ១០១៨ ព្រោះងាយស្រួលធ្វើតែការលំបាក គឺប្រជាពលរដ្ឋមិនមានរូបថត ។ គជប កំពុងសុំឱ្យអាជ្ញាធរឃុំសង្កាត់សហការជាមួយគណៈកម្មាធិការបោះឆ្នោតខេត្ត ដើម្បីជំរុញឱ្យមានរូបថតពីចំងាយដើម្បីត្រៀមសំរាប់បោះឆ្នោតនៅពេលខាងមុខ ។

ទាក់ទងទៅនឹងការងារនៅក្នុងខេត្ត គជប បានធ្វើតាំងពីដើមឆ្នាំមានដូចជា ទី១. ត្រៀមសំរាប់ការចុះឈ្មោះបោះឆ្នោត គឺប្រជាពលរដ្ឋដែលមិនទាន់មានឈ្មោះក្នុងបញ្ជីអាចមកទាក់ទងព័ត៌មាន បំពេញឯកសារត្រៀម។ ទី២. ធ្វើទំរង់ ១០១៨ និងឯកសារសំរាប់បោះឆ្នោត ។ ទី៣. ការស្រង់ស្ថិតិ និងការប៉ាន់ស្មានចំនួនប្រជាពលរដ្ឋ ការពិនិត្យលើទីតាំងការិយាល័យបោះឆ្នោតដែលត្រូវបង្កើតថ្មី ។ ក្នុងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ២០០៥ កន្លងមកនេះមានការិយាល័យបោះឆ្នោតប្រហែល ១៣ ៩៤៧ មានអ្នកបោះឆ្នោត ៦ លាន ៧ សែននាក់ ។ នីតិវិធីនៃការកំណត់ទីតាំងការិយាល័យ គឺសូមឱ្យអាជ្ញាធរឃុំសង្កាត់ ហើយនៅចំពោះមុខទៀតគឺមានគណៈកម្មាធិការរៀបចំការបោះឆ្នោតឃុំសង្កាត់ដែលជាអ្នកពិនិត្យចុងក្រោយទៀតនៅពេលបង្កើត តែអាជ្ញាធរឃុំសង្កាត់ជាអ្នកមើលទីតាំងកន្លែងណាឱ្យសមនឹងចំនួនប្រជាពលរដ្ឋដែលមាននៅទីនោះដើម្បីកំណត់ទីតាំងការិយាល័យ ។ មានការប្តូរទីតាំងការិយាល័យខ្លះមិនមែនប្តូរពីមួយកន្លែងទៅមួយកន្លែងឆ្ងាយទេ ។ ឧទាហរណ៍ ទីតាំងការិយាល័យនៅផ្ទះឥឡូវខំបង្វិលមកនៅសាលារៀន ឬទីសាធារណៈក្បែរៗនោះវិញ ។ គជប ធ្វើពីចំងាយនេះដើម្បី ទី១. ជូនព័ត៌មានប្រជាពលរដ្ឋឱ្យបានដឹងច្បាស់លាស់។ ទី២. ជូនដំណឹងដល់គណបក្សនយោបាយ និង NGOs ដែលទាក់ទងនឹងការបោះឆ្នោតឱ្យបានដឹងទាំងអស់គ្នាមុន ចៀសវាងនូវបញ្ហាដែលថាការប្តូរការិយាល័យមិនដឹង ។

គជប រៀបចំគម្រោងមួយទៀតនៅមុនការចុះឈ្មោះប្រចាំឆ្នាំនេះ ប្រសិនបើរកថវិកាបាននឹងធ្វើនៅក្នុង ខែ៧ ខែ៨ គឺការផ្តល់ប័ណ្ណព័ត៌មានដល់អ្នកបោះឆ្នោតទាំងអស់ដែលមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត ៦ លាន ៧ សែននាក់នេះ ។ ការផ្តល់ប័ណ្ណនេះគឺដើម្បីបម្រើឱ្យការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះប្រចាំឆ្នាំ ២០០៦ នេះសំដៅសំរាប់ការបោះឆ្នោតឃុំ ២០០៧ ។ ការចែកប័ណ្ណសាកល្បងក្នុង ១០ ឃុំនេះ គជប បានទិន្នន័យមួយចំនួនដែលបម្រើឱ្យផលប្រយោជន៍នៃការចុះឈ្មោះបោះឆ្នោត។ ទី១. គជប ដឹងថាអ្នកដែលផ្លាស់ប្តូរទីលំនៅនៅក្នុងឃុំសង្កាត់នេះ ចំនួនដែលដឹងនេះនឹងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ។ ទី២. គជប ដឹងចំនួនអ្នកស្លាប់ទោះបីមិនបាន ១០០ ភាគរយក៏ដោយ ។ ទី៣. គជប ដឹងអ្នកដែលមានអាសយដ្ឋានមិនច្បាស់លាស់ក្នុងឃុំសង្កាត់ ក្នុងករណីអាសយដ្ឋានមិនច្បាស់លាស់នេះបើក្នុងឆ្នាំមិនមានការបោះឆ្នោតមិនជាបញ្ហាទេ តែក្នុងឆ្នាំដែលមានការបោះឆ្នោតបញ្ហាដែលមានចោទច្រើន គឺរឿងអាសយដ្ឋាន ។ ពីមុនមកច្បាប់កំណត់ច្បាស់ណាស់ ទាល់តែអ្នកនៅក្នុងឃុំសង្កាត់ហើយមានសៀវភៅគ្រួសារច្បាស់លាស់ ទើបចុះឈ្មោះឱ្យដល់ក្រោយមកអនុញ្ញាតឱ្យមានតំណាង ២ នាក់គ្រាន់តែធានាថាអ្នកនោះនៅក្នុងឃុំសង្កាត់អាចចុះឈ្មោះ ។ ដោយសារករណីនេះអ្នកដែលមកធ្វើការនៅភ្នំពេញ ជួលផ្ទះគេនៅ ឬក៏មកស្នាក់នៅជាមួយគេ មករៀនសូត្រ មកធ្វើការមួយរយៈពេល ឧទាហរណ៍ដូចទាហានផ្លាស់ទៅរៀនសាលាទាហាននៅកំពង់ស្ពឺមួយរយៈក៏មានសិទ្ធិចុះឈ្មោះនៅទីនោះបានដែរ ។ នៅពេលចុះឈ្មោះនៅទីនោះហើយមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ពេលចប់ការបោះឆ្នោត គាត់ផ្លាស់ទៅផ្ទះវិញ ឈ្មោះក្នុងបញ្ជីមិនអាចលុបបាន ព្រោះមិនមានឯកសារអ្វីត្រូវលុបសោះ ។ ករណីនេះមានបន្សល់អ្នកដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ហើយមិនមានអាសយដ្ឋានពិតប្រាកដក្នុងឃុំសង្កាត់ ។ ឧទាហរណ៍ នៅតាមព្រំដែនប៉ោយប៉ែត គ្រាន់តែមួយឃុំប៉ោយប៉ែតមានរហូតដល់ ៦០ ជាងការិយាល័យ ក្នុងនោះអ្នកដែលនៅក្នុងប៉ោយប៉ែតមែនទែនប្រហែលជាជាង ២ ម៉ឺននាក់ទេ អញ្ចឹងហើយទើបមានការប្តឹងតវ៉ានៅឆ្នាំ ២០០៣ ដែលថាអ្នកប៉ោយប៉ែតបោះបានតែ ៥០ ភាគរយនៅសល់ ៥០ ភាគរយទៀតមិនមកបោះឆ្នោតហេតុអ្វីបានបាត់អ្នកបោះឆ្នោតច្រើនម្លេះ ? នេះជាបញ្ហាមួយ

ដែលបន្សល់នូវការលំបាកនៅលើបញ្ជីបោះឆ្នោតដែលត្រូវធ្វើការសំអាត ។ ការសាកល្បងចែកប័ណ្ណជូនព័ត៌មានដល់អ្នកបោះឆ្នោតនៅក្នុង ១០ ខេត្ត ១០ ឃុំ មានឃុំមួយនៅតាមព្រំដែនចែកមិនបាន៥០ភាគរយនៃអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត។ ទិន្នន័យដែលទទួលបានពីការចែកសាកល្បងនេះ គជប រៀបចំគម្រោងមួយទៀតនឹងធ្វើការជូនប័ណ្ណព័ត៌មានដល់អ្នកបោះឆ្នោតទាំងអស់ ដើម្បីទទួលទិន្នន័យទាំងអស់នោះជាមូលដ្ឋានឱ្យស្មៀនឃុំសង្កាត់ និងក្រុមប្រឹក្សាឃុំសង្កាត់ក្នុងការជំរះបញ្ជីនិងពិនិត្យបញ្ជីឈ្មោះនៅឆ្នាំ ២០០៦ សម្រាប់ការបោះឆ្នោតឃុំសង្កាត់នេះ ។ គជប កំពុងតែរៀបចំនីតិវិធីក្នុងការចែកប័ណ្ណផ្តល់ព័ត៌មាននេះ ដោយឱ្យអាជ្ញាធរចែក អាចក្រុមប្រឹក្សាឃុំសង្កាត់ ស្មៀនឃុំ សហការជាមួយគណៈកម្មាធិការខេត្តរៀបចំការបោះឆ្នោតនិងប្រធានភូមិ ដើម្បីឱ្យចែកឯកសារនេះដល់អ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីនៅក្នុងភូមិ ។

បញ្ហាមួយទៀតទាក់ទងនឹងខេត្តកោះកុង ដែលខប់សែលប្រ៉មបានជួបនិងលើកឡើងនៅក្នុងកិច្ចប្រជុំនេះ គឺខេត្តកោះកុងក៏មានស្ថានភាពស្មុគស្មាញដែរពីបញ្ជីឈ្មោះអ្នកបោះឆ្នោតដោយសារ ទី១. ភូមិសាស្ត្រនៅតាមកោះឆ្ងាយៗ ហើយឃុំខ្លះមានមនុស្សតិចណាស់ និងក្តាប់ចំនួនស្ថិតិមិនបានទៀងទាត់ ព្រោះអ្នកទៅរកស៊ីនៅទីនោះចេញទៅថៃ អ្នកត្រឡប់មកវិញ ហើយអ្នកដំណើរច្រើន ជាងដូចនេះទើបនៅក្នុងបញ្ជីប៉ាន់ស្មានសម្រាប់ការចុះឈ្មោះបោះឆ្នោតឆ្នាំ ២០០៥ នេះចំនួនឈ្មោះដែលគ្រប់ ១៨ ឆ្នាំនៅក្នុងខេត្តកោះកុងចង់តិចជាងចំនួនឈ្មោះអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ។ គជប ស្រាវជ្រាវថាហេតុអ្វីបានជាមានករណីនេះកើតឡើង? នេះដោយសារតែនៅពេលអាជ្ញាធរស្រង់ស្ថិតិសម្រាប់ការចុះឈ្មោះបោះឆ្នោតអ្នកទាំងអស់នោះចេញទៅកន្លែងផ្សេង នាំឱ្យបាត់ចំនួនធ្វើឱ្យចំនួនជាក់ស្តែងតិចជាងចំនួនឈ្មោះដែលមាននៅក្នុងបញ្ជីបោះឆ្នោត ។ ដូច្នេះមានការស្មុគស្មាញលើបញ្ជីបោះឆ្នោតនៅតាមខេត្តដែលជិតព្រំដែន ។ គជប កំពុងសហការជាមួយអាជ្ញាធរថាធ្វើយ៉ាងម៉េចដើម្បីឱ្យត្រឹមត្រូវជាមួយគ្នារវាងមនុស្សមែនទែននិងឈ្មោះក្នុងបញ្ជី ។ ជាដំណោះស្រាយទី១.សាកល្បងចែកប័ណ្ណព័ត៌មានថែមមួយទៀត ទី២. រង់ចាំនៅពេលដែលអត្រានុកូលដ្ឋានដែលក្រសួងមហាផ្ទៃកំពុងដំណើរការ និងការចេញអត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋ ដែលអាចជាមូលដ្ឋានសំខាន់ដល់ការរៀបចំបញ្ជីបោះឆ្នោត ។ នៅពេលមានអត្តសញ្ញាណប័ណ្ណមានអត្រានុកូលដ្ឋានត្រឹមត្រូវនោះ បញ្ជីបោះឆ្នោតលែងចោទជាបញ្ហាទៀតហើយ ។

លោក **ឱក សេរី សោភក្តិ** សំដែងការអបអរសារទរដោយបានឮថាការិយាល័យប៉ាន់ស្មានទាំង ១៤.៥០០ ការិយាល័យបោះឆ្នោតសម្រាប់បំរើឱ្យការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់នៅឆ្នាំក្រោយនេះ គឺចៀសយ៉ាងណាមិនឱ្យដាក់ទីតាំងនៅក្នុងផ្ទះបុគ្គល ។ នេះជាការល្អហើយជាការប្រឹងប្រែងមួយដែលជាក់ស្តែង ។ នៅក្នុងកិច្ចប្រជុំខប់សែលខមលើកទី ៨ បានរាយការណ៍ជូនអង្គប្រជុំថានៅខេត្តស្ទឹងត្រែងមានទំនាស់ដោយសារការជ្រើសរើសទីតាំងនៅក្នុងផ្ទះឯកជននេះ ។ ដូច្នេះអ្វីដែលឯកឧត្តមអគ្គលេខាធិការមានប្រសាសន៍ជាដំណោះស្រាយមួយជាក់ស្តែង ហើយ **ខប់សែល** សង្ឃឹមថានៅគ្រប់ទីកន្លែងនឹងមានការពិបាកក្នុងការរកការិយាល័យបោះឆ្នោត ១៤.៥០០ ដែលការប្រឹងប្រែងនេះដើម្បីជាដំណោះស្រាយកុំឱ្យមានទំនាស់ ។

លោក **ម៉ារ សុផល** មន្ត្រីសម្របសម្រួលផ្នែកអង្កេត-អង្គការខុមហ្វ្រែល បានចាប់អារម្មណ៍ និងមានសំណួរមួយចំនួន ទី១. មានការព្រួយបារម្ភណ៍ពីការលើកឡើងទាក់ទងនឹងគុណភាពរបស់បញ្ជីឈ្មោះអ្នកបោះឆ្នោត ដែល ឯកឧត្តម ទេព នីថា បានលើកឡើងអំពីបញ្ហាដែលគួរឱ្យព្រួយបារម្ភណ៍ជាច្រើនទាក់ទងនឹងព័ត៌មានរបស់អ្នកបោះឆ្នោត ក៏ដូចជាការផ្លាស់ប្តូរទីលំនៅរបស់អ្នកបោះឆ្នោតដែលធ្វើឱ្យបញ្ជីបោះឆ្នោតមួយចំនួនមានភាពច្រើនលើសលុបបហួសពីការពិតជាក់ស្តែង ។ យោងតាមលទ្ធផលដែលខាង គជប បានធ្វើកន្លងមកទាក់ទងទៅនឹងការចែកប័ណ្ណអ្នកបោះឆ្នោតចំនួន ១០ ឃុំ លោកមានការកត់សំគាល់មួយលើលទ្ធផលដែលរកឃើញអំពីឈ្មោះស្ទួន ក្នុងនោះមានឃុំខ្លះមានរហូតទៅដល់ ៩៣ ឈ្មោះស្ទួនតើមកពីបញ្ហាអ្វីដែលបណ្តាលឱ្យមានឈ្មោះស្ទួនច្រើនយ៉ាងនេះ? ទាក់

ទងនឹងអាសយដ្ឋាន ដែលក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលខុមហ្វ្រែលបានទទួលពី គជប មក កត់សំគាល់ឃើញថាអាសយដ្ឋាន របស់អ្នកបោះឆ្នោតនីមួយៗ ជាពិសេសនៅតាមជនបទពិបាករក ដោយសារជួនកាលមានត្រឹមតែភូមិនិងឃុំតែម្តង មិនដឹងថាលេខផ្ទះ លេខផ្លូវពេលខ្លះពិបាករក ព្រោះថាខុមហ្វ្រែលក៏ធ្លាប់បានធ្វើការចុះពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត ។ ចំពោះករណីចែកប័ណ្ណដែល គជប សង្ឃឹមថានឹងប្រើប្រាស់យន្តការមេភូមិនេះដើម្បីជួយក្នុងការចែកប័ណ្ណអ្នកបោះឆ្នោត បើក្នុងករណីដែលមេភូមិមានចេតនា ឬអចេតនាក្នុងការមិនបានផ្តល់ប័ណ្ណបោះឆ្នោតទៅដល់អ្នកបោះឆ្នោត តើ គជប មានយន្តការអ្វីដើម្បីតាមដានថាតើអ្នកបោះឆ្នោតគ្រប់រូបទទួលបានប័ណ្ណបោះឆ្នោតនេះពី គជប?

ទាក់ទងនឹងដំណើរការត្រៀមរៀបចំក្នុងការសង្កេតការណ៍បោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ខាងមុខនេះ ខុមហ្វ្រែលបានរៀបចំផែនការរបស់ខ្លួនរួចហើយ ។ ក្នុងនោះគម្រោងសំខាន់មួយដែលទាក់ទងនឹងបញ្ហាដែល ខប់សែល កំពុងជជែកគ្នានេះ គឺ គុណភាពបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលខុមហ្វ្រែលធ្លាប់បានធ្វើម្តងរួចមកហើយនៅក្នុងឆ្នាំ ២០០៣ ដោយការពិនិត្យគុណភាព បញ្ជីឈ្មោះបោះឆ្នោត Audit Voter List ដោយជ្រើសរើសគំរូចំនួន ៤០០ នាក់ទូទាំងប្រទេស ដើម្បីនឹងធ្វើការពិនិត្យផ្ទៀងផ្ទាត់រវាងបញ្ជីឈ្មោះអ្នកបោះឆ្នោតជាមួយនឹងព័ត៌មានជាក់ស្តែងដែលអ្នកបោះឆ្នោតមាន ដូចជាអត្តសញ្ញាណប័ណ្ណនិងប័ណ្ណបោះឆ្នោត ។ ក្នុងនោះ ខុមហ្វ្រែលធ្លាប់បានផ្សព្វផ្សាយ និងជម្រាបជូន គជប រួចម្តងមកហើយ ។ លើកនេះដោយសារតែការពិនិត្យមើលទៅថាចំនួន ៤០០ នាក់ក្នុងចំណោមជិត ៧ លាននាក់ ដែលជ្រើសរើសដោយចៃដន្យពីបញ្ជីឈ្មោះអ្នកបោះឆ្នោត មានលក្ខណៈមិនអាចតំណាងឱ្យការវាយតម្លៃគុណភាពបញ្ជីឈ្មោះទូទាំងប្រទេសបាន ខុមហ្វ្រែល ប្តូរយុទ្ធសាស្ត្រមកជ្រើសរើសក្នុងចំណោមតែ ១០ ខេត្ត ហើយចំនួនគំរូគឺបង្កើនរហូតទៅដល់ ៤២០ នាក់ ដោយសារតែនៅពេលដែលជ្រើសរើស ១០ខេត្ត បែងចែកសមាមាត្រអ្នកបោះឆ្នោតទៅនឹងចំនួនបញ្ជីអ្នកបោះឆ្នោតក្នុងខេត្តក្រុងមួយដើម្បីនឹងសមាមាត្រទៅនឹងចំនួនអ្នកបោះឆ្នោតក្នុង ១០ខេត្ត ដែលជ្រើសរើស ធ្វើឱ្យសមាមាត្របានតិចនៅក្នុងក្រុងប៉ៃលិន និងខេត្តរតនៈគីរី ដែលមានអ្នកបោះឆ្នោតត្រឹមតែ ៣-៦ នាក់ ។ កាលពីមុន ខុមហ្វ្រែល មិនមានគោលបំណងថាវាយតម្លៃជាភាពតំណាងឱ្យបញ្ជីឈ្មោះទូទាំងប្រទេសដែរ គ្រាន់តែជាការសិក្សាស្វែងយល់អំពីភាពសុក្រឹតនៃបញ្ជីឈ្មោះឆ្នោតតាមលទ្ធភាពធ្វើបាន ។ គម្រោងនេះធ្វើឡើងដើម្បីស្វែងរកព័ត៌មានជម្រាបជូន គជប អំពីគុណភាពនៃបញ្ជីឈ្មោះបោះឆ្នោត។ គោលបំណងសំខាន់ៗទាក់ទងនឹងគុណភាពបញ្ជីឈ្មោះ គឺ ខុមហ្វ្រែល ចង់ស្វែងរកអ្នកបោះឆ្នោតខ្មោច ដែលអត់មានមនុស្សតែមានឈ្មោះអ្នកបោះឆ្នោត ។

ទាក់ទងនឹងនីតិវិធីក្នុងការចុះឈ្មោះបោះឆ្នោត ដែលមានសាក្សីពីរនាក់អាចធានាឱ្យអ្នកបោះឆ្នោតចុះឈ្មោះបាន ដូចជាករណីនៅខាងប៉ោយប៉ែត គ្រាន់តែផ្លាស់ប្តូរទីលំនៅដើម្បីទៅរកទទួលទាននៅទីកន្លែងនោះហើយស្នាក់នៅក្នុងរយៈពេល ៦ ខែ ឬក៏មួយឆ្នាំ ស្មៀនឃុំអាចអនុញ្ញាតឱ្យមានមនុស្សពីរនាក់ដើម្បីធានាអ្នកបោះឆ្នោតរូបនោះ បញ្ហានេះជាការព្រួយបារម្ភណ៍មួយ ប្រសិនបើនីតិវិធីនេះនៅតែអនុវត្តតទៅទៀតធ្វើឱ្យគុណភាពបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅតែជួបបញ្ហា ។ ខុមហ្វ្រែល សូមស្វាគមន៍ចំពោះព័ត៌មានដែលរាជរដ្ឋាភិបាលជាពិសេសក្រសួងមហាផ្ទៃបានខិតខំធ្វើអត្តសញ្ញាណប័ណ្ណចែកជូនដល់ប្រជាពលរដ្ឋឱ្យបានគ្រប់គ្នា គឺជាការមួយល្អ ។ ចំពោះទម្រង់ ១០១៨ នៅតាមជនបទស្រុកស្រែចម្ការពិបាកនឹងរករូបថតបិទ ។ កន្លងមកខាង ខុមហ្វ្រែល បានរកឃើញច្រើនពាក់ព័ន្ធនឹងបញ្ហារូបថត ហើយក៏បានរកឃើញបញ្ហាមួយចំនួនទម្រង់ ១០១៨ មិនមានបិទរូបថតហើយអាចចុះឈ្មោះបាន ។

លោក **ឱក សេរី សោភក្តិ៍** បានកោតសរសើរចំពោះ ខុមហ្វ្រែល ដែលមានគម្រោងធ្វើការអង្កេត ដើម្បីពិនិត្យមើលគុណភាពនៃបញ្ជីបោះឆ្នោតដែល គជប រួមសហប្រតិបត្តិការជាមួយនឹងក្រសួងមហាផ្ទៃតាមរយៈក្រុមប្រឹក្សាឃុំសង្កាត់ និងស្មៀនឃុំសង្កាត់ ។

ឯកឧត្តម **ទេព នីថា** បានរបាយការណ៍របស់ ខុមហ្វ្រែល ទាក់ទងនឹងបញ្ជីបោះឆ្នោតកន្លងមកនេះមានចំណុចល្អច្រើនជាមូលដ្ឋានដល់ការពិចារណារបស់ គជប ក្នុងការធ្វើសកម្មភាព និងរៀបចំផែនការធ្វើឱ្យបញ្ជីបោះឆ្នោតច្បាស់លាស់មានគុណភាពល្អ ។ ឯកឧត្តមលើកឡើងថាបញ្ជីបោះឆ្នោតមានតាំងពីឆ្នាំ ១៩៩៨ ។ ការចុះឈ្មោះនៅឆ្នាំ ១៩៩៨ គឺជានីតិវិធីផ្សេងមួយដែល គជប បង្កើតក្រុមដើរចុះឈ្មោះដោយមួយក្រុមចុះ ៩ ការិយាល័យបោះឆ្នោត ។ ការចុះឈ្មោះពេលនោះខុសពីពេលបច្ចុប្បន្ន គឺចុះឈ្មោះហើយចែកប័ណ្ណបោះឆ្នោតឱ្យតែម្តង ។ ចន្លោះចាប់ពីឆ្នាំ ១៩៩៨ មកដល់ឆ្នាំ ២០០២ គជប មិនបានធ្វើអ្វីទេ លុះដល់ឆ្នាំ ២០០២ ទើប គជប ធ្វើការចុះឈ្មោះម្តងទៀតដោយធ្វើបច្ចុប្បន្នភាពផង ចុះឈ្មោះផង ដោយអ្នកដែលមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតទាំងអស់ត្រូវមកបង្ហាញខ្លួនដើម្បីរក្សាឈ្មោះបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ។ ក្រោយឆ្នាំ ២០០២ មកដល់ឆ្នាំ ២០០៣ នីតិវិធីចុះឈ្មោះផ្សេងមួយទៀតគឺប្រគល់ការងារចុះឈ្មោះឱ្យទៅក្រុមប្រឹក្សាឃុំសង្កាត់រួមមានស្មៀនសង្កាត់ជាអ្នកចុះឈ្មោះ ។ ការចុះឈ្មោះចុងក្រោយពីឆ្នាំ ២០០៣ មកដល់ឥឡូវនេះជានីតិវិធីមួយនៃការចុះឈ្មោះដែលសមស្របជាង ព្រោះអ្នកដែលចុះឈ្មោះគឺអាជ្ញាធរនិងស្មៀនឃុំសង្កាត់ដែលនៅជាមួយប្រជាពលរដ្ឋផ្ទាល់ ប៉ុន្តែអ្វីដែលមិនទាន់បានល្អ គឺឈ្មោះដែលមានពីមុនមកគាត់ក្លាប់មិនបានអស់ ។ ពីឆ្នាំ ១៩៩៨ អ្នកដែលមានប័ណ្ណបោះឆ្នោតអ៊ុនតាក់ហើយក៏មកចុះឈ្មោះបានដែរ ។

ចំនុចខ្វះខាតមួយទៀតទាក់ទងនឹងការចុះឈ្មោះជំនាន់អ៊ុនតាក់គឺ បញ្ហាសញ្ជាតិមានអ្នកធានាសញ្ជាតិបាន ព្រោះកាលនោះច្បាប់សញ្ជាតិមិនមានទេ ដល់ពេលចេញច្បាប់សញ្ជាតិមក សញ្ជាតិធានាមិនបានទេទាល់តែមានឯកសារត្រឹមត្រូវ ។ គជប កំពុងសំអាតជាបណ្តើរៗ ។ ឧទាហរណ៍ ឆ្នាំ ២០០៤ គជប ចុះឈ្មោះឡើងវិញ លុបឈ្មោះអ្នកស្លាប់ អ្នកផ្លាស់ប្តូរទីលំនៅ អ្នកដែលមានឈ្មោះមិនត្រឹមត្រូវ ៨ ម៉ឺននាក់ក្រោយមកលុប ៦ ម៉ឺននាក់ជាងទៀត ។ ជួនកាលបើសន្មត់ថាប្រជាពលរដ្ឋនេះមិននៅទីនោះទេ មានឯកសារសុំផ្លាស់ប្តូរចេញទើបអាចលុបបាន ប៉ុន្តែបើសន្មត់គ្មានឯកសារគ្រប់គ្រាន់ស្រាប់តែថ្ងៃបោះឆ្នោតគាត់មកបោះមិនមានឈ្មោះ មានបញ្ហា ។ មានលេខក្នុងបញ្ជីឈ្មោះបោះឆ្នោត និងលេខជាក់ស្តែងមិនសូវស៊ីគ្នាប្រហែលមិនដល់ ២ ភាគរយផង ។ គជប បានសាកល្បងធ្វើដែរថាជាទូទៅអ្នកបោះឆ្នោតឆ្នាំ ២០០៣ គឺមានអ្នកមកបោះឆ្នោត ៨៣ ភាគរយ មានន័យថាយ៉ាងហោចណាស់ក៏ជាង ៨០ ភាគរយ នៃបញ្ជីបោះឆ្នោតត្រឹមត្រូវហើយ តែអ្នកអវត្តមានមិនបានមកបោះឆ្នោតនៅឃុំសង្កាត់នឹងស្រាវជ្រាវទៀត ។ មានអ្នកទៅរកស៊ីនៅក្រៅ មានកូនសិស្សទៅរៀននៅក្រៅ មានអ្នកមានបញ្ហាពន្ធធនាគារ មានអ្នកឈឺថ្កាត់ ក្នុងនោះមានប្រហែលជិត១០ ភាគរយ នៅក្នុងការិយាល័យមួយ ។ ដូច្នេះ គជប អាចប៉ាន់ស្មានថាបញ្ជីបោះឆ្នោតមានជាង ៩០ ភាគរយ ដែលត្រឹមត្រូវ ។

ករណីខ្លះពិបាកធ្វើ ដូចជានៅប៉ោយប៉ែត កោះកុង អ្នកគ្រាន់តែស្នាក់នៅហើយចុះឈ្មោះបាន ដោយសារទី១. ច្បាប់បោះឆ្នោតមិនមាននិយាយថាទៅនៅបានប៉ុន្មានថ្ងៃ ទើបអាចចុះឈ្មោះបានទេ ។ មានកាតមួយអាចបញ្ជាក់ថាមានសញ្ជាតិខ្មែរហើយ បន្ទាប់មកលក្ខ័ណ្ឌដែលលំបាកជាងគេគឺទីលំនៅ ។ កាលណាជួលផ្ទះ ឬមានពីរនាក់ដែលមានឈ្មោះបោះឆ្នោតនៅឃុំមកធានាថាអ្នកនោះមានទីលំនៅជួលផ្ទះអាចចុះឈ្មោះបានដែរ ។ ការងារលក្ខ័ណ្ឌទីលំនៅនេះបើលំបាកពេកមិនបានទេ ជាពិសេសនៅពេលបោះឆ្នោតអាចមានទំនាស់ធំ ។ ឧទាហរណ៍ អ្នកមករៀននៅភ្នំពេញនៅឆ្នាំ ២០០២ និងឆ្នាំ ២០០៣ គជប មិនឱ្យចុះឈ្មោះនៅភ្នំពេញទេព្រោះមកជួលផ្ទះនៅដោយគ្មានឯកសារបញ្ជាក់ទីលំនៅ ។ ពេលនោះគាត់តវ៉ារហូតដល់មុនពេលបញ្ចប់ការចុះឈ្មោះមួយអាទិត្យ គជប ចេញសេចក្តីណែនាំមួយផ្សេងទៀតដើម្បីសម្រួលការងារនេះឱ្យគាត់ចុះឈ្មោះបាន ព្រោះបើសិនមិនឱ្យគាត់ចុះឈ្មោះនៅទីនោះទេ ពេលបោះឆ្នោតគាត់មិនបានបោះឆ្នោត ហើយគាត់ក៏មិនវិលទៅភូមិកំណើតដើម្បីបោះឆ្នោតវិញដែរ ដែលនាំឱ្យបាត់សម្លេងច្រើន ។ តួលេខអ្នកបោះឆ្នោតនៅឆ្នាំ ២០០២ មានភាគរយឡើងមែន ប៉ុន្តែអ្នកដែលចុះឈ្មោះបោះឆ្នោតថយតិចជាងពេលបោះឆ្នោតឆ្នាំ ១៩៩៨ មូលហេតុ

រឿងបញ្ជាក់ទីលំនៅនឹងពេក ។ ដូច្នេះហើយបានជាវិសោធនកម្មក្រោយច្បាប់បោះឆ្នោតតំណាងរាស្ត្របានបន្ធូរបន្ថយលក្ខណ្ឌទីលំនៅ លក្ខណ្ឌដែលធានាសាក្សីបានមានតែ អាយុ អត្តសញ្ញាណ និងទីលំនៅដែលមានសាក្សីធានាពីរនាក់បាន ។

បញ្ហាឈ្មោះស្ទួននៅក្នុងឃុំមានតិចទេ ដោយសារគាត់ចេញពីភូមិមួយទៅភូមិមួយទៀតនៅក្នុងឃុំ ហើយគាត់អត់បានលុប ឬក៏ស្មៀនឃុំមិនបានលុបឈ្មោះចេញ ហើយការលុបឈ្មោះស្ទួននៅក្នុងឃុំសង្កាត់ងាយទេ តែការស្ទួនក្រៅឃុំសង្កាត់ឬក៏ឆ្លងខេត្តទើបមានការលំបាកព្រោះត្រូវធ្វើទំរង់សំរាប់លុបឈ្មោះស្ទួន ហើយយើងបានធ្វើនៅឆ្នាំ ២០០៤ និង ២០០៥ គឺ គជប ស្រង់យកឈ្មោះស្ទួននៅក្នុងកុំព្យូទ័រមកឈ្មោះស្ទួនមាននៅឯណាខ្លះ ផ្ទៀងតាំងពីទិន្នន័យអាយុ ភេទ ត្រឹមត្រូវគ្នាទេ ហើយឱ្យឈ្មោះនោះទៅទាំងសងខាង ។ ឧទាហរណ៍ ឈ្មោះស្ទួនមួយនៅភ្នំពេញ មួយនៅកំពង់ស្ពឺ គជប ឱ្យឈ្មោះស្ទួនមួយបញ្ជីនៅភ្នំពេញតើស្ទួននៅខេត្តណាខ្លះ បន្ទាប់មកឱ្យឈ្មោះមួយទៀតទៅខេត្តណាមួយដែលមានឈ្មោះមួយទៀតឱ្យគណៈកម្មាធិការខេត្ត និងក្រុមប្រឹក្សាឃុំស្មៀនឃុំពិនិត្យមើលឈ្មោះ ហើយក្នុងករណីដែលឈ្មោះនោះនៅក្នុងឃុំរបស់គាត់ហៅអ្នកនោះមកសួរថា ឥឡូវមានឈ្មោះពីរនៅក្នុងឈ្មោះបោះឆ្នោត គាត់រើសឈ្មោះយកកន្លែងណា? ករណីលុបឈ្មោះស្ទួននេះ គជប បានលុបច្រើន ក្នុងពីរឆ្នាំ ២០០៤ និង២០០៥ ។ អ្នកទៅចុះឈ្មោះបោះឆ្នោតទី១ អាចថាគាត់ខ្ជិលដែរ ពេលសួរគាត់ថាធ្លាប់បោះឆ្នោតទេ គាត់ឆ្លើយថាមិនដែលទេ ហើយបើគាត់ឆ្លើយអញ្ចឹងហើយ គ្មានអ្វីទៅពិនិត្យទៀតព្រោះត្រូវចុះឈ្មោះឱ្យ នៅពេលរកឈ្មោះក្នុងបញ្ជីបានដឹងថាស្ទួននៅក្រៅឃុំសង្កាត់ ។ ការងារនេះមានការលំបាកតែទោះជាយ៉ាងណាក៏ គជប បានធ្វើនឹងខិតខំធ្វើទៀត ។ បញ្ហាអាសយដ្ឋាននៅតាមមូលដ្ឋានផ្ទះគ្មានលេខទេ ដាក់បានត្រឹមភូមិគឺច្បាស់លាស់ហើយ បើចង់ដឹងផ្ទះលេខប៉ុន្មាននៅតាមភូមិអត់ទាន់មានទេ ថ្ងៃក្រោយប្រសិនបើមានលេខ គជប បំពេញតាមក្រោយបាន។

ទាក់ទងនឹងមេភូមិប័ណ្ណជូនព័ត៌មានមិនមែនជាប័ណ្ណបោះឆ្នោតទេ ទិសដៅទៅមុខប្រើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដើម្បីបោះឆ្នោត ។ បើមិនមានអត្តសញ្ញាណប័ណ្ណ ច្បាប់អនុញ្ញាតឱ្យមានប៉ាស្ព័រ ប័ណ្ណមន្ត្រីរាជការ អត្តសញ្ញាណប័ណ្ណជាតិខ្មែរ សៀវភៅគ្រួសារដែលមានរូបថតដើម្បីអាចបោះឆ្នោតបាន ។ ប្រសិនបើក្រសួងមហាផ្ទៃចេញអត្តសញ្ញាណប័ណ្ណជាតិខ្មែរបានកម្រិតណានៅសល់ចន្លោះគឺប្រើទម្រង់ ១០១៨ របស់ គជប ដើម្បីបោះឆ្នោតដោយមានបិទរូបថតសម្រាប់បោះឆ្នោត ។ ចំពោះមេភូមិ ទោះបីថ្មីក៏ដោយទោះបីចាស់ក៏ដោយ គជប នឹងប្រើប្រាស់មេភូមិនៅពេលខាងមុខនេះ ប្រសិនរើសបានមេភូមិថ្មី នឹងប្រើមេភូមិថ្មី ប្រសិនមិនទាន់បានទេប្រើមេភូមិចាស់ដើម្បីចែកសេចក្តីជូនដំណឹងដល់អ្នកបោះឆ្នោត ។

បញ្ហាមួយទៀត ១០១៨ មិនមានរូបថតចុះឈ្មោះបាន នៅពេលចុះឈ្មោះបោះឆ្នោតបើសិនមិនមានទីលំនៅច្បាស់លាស់ឯកសារបញ្ជាក់អត្តសញ្ញាណ ឯកសារបញ្ជាក់អាយុ ត្រូវមានសាក្សីពីរនាក់ទៅធានា ការធានានេះគ្រាន់តែចំពោះមេឃុំ ហើយបញ្ជាក់ថាគាត់ពិតជានៅក្នុងឃុំសង្កាត់នេះពិតមែន មិនបាច់បិតរូបថតក៏បានដែរ ។ ក៏ប៉ុន្តែនៅពេលបោះឆ្នោត ១០១៨ នេះដាច់ខាតត្រូវតែមានរូបថតទើបបោះឆ្នោតបាន ។ ចំពោះលក្ខណ្ឌផ្សេងទៀតដែលថានីតិវិធីសាក្សីពីរនាក់គឺច្បាប់កំណត់ គជប គ្រាន់តែអនុវត្តតាមច្បាប់ ។ ចំពោះមុខនេះនៅពេលក្រសួងមហាផ្ទៃធ្វើកាតប្រជាពលរដ្ឋបានច្រើន ហើយការចុះអត្រានុកូលដ្ឋានឮថាបានច្រើន នៅសល់មួយចំនួនតូចទេ ដែលអាចនឹងសម្រួលព្រោះបញ្ហាស្ថិតិ អត្តសញ្ញាណ របស់ប្រជាពលរដ្ឋជាបញ្ហាដែលទាមទារចាំបាច់លក្ខណ្ឌក្នុងការរស់នៅក្នុងសង្គមចំពោះមុខ ហើយប្រជាពលរដ្ឋក៏មានការភ្ញាក់រលឹកច្រើនធ្វើការងារនេះ ។ នៅឆ្នាំ ២០០៧ អាចអត្តសញ្ញាណប័ណ្ណបានច្រើនហើយបង្កលក្ខណៈងាយស្រួល និងច្បាស់លាស់ដល់ការបោះឆ្នោត ។

លោក **ម៉ារ សុផល** លើកថាប្រហែលនៅខែ ១០-១១ ឆ្នាំ ២០០៦ ខុមហ្វ្រែលខំព្យាយាមឱ្យបានរឿងការពិនិត្យបញ្ជីឈ្មោះ។ នៅខេត្តកំពង់ចាមនៅពេលដែលខុមហ្វ្រែលធ្វើឃើញមានរហូតដល់ ៩០ នាក់ជាងមានបញ្ហាឈ្មោះនេះ ។

លោក **ឱក សេរី សោភ័ក្តិ** បានជម្រាបជាព័ត៌មានថាដោយសារមាននិន្នាការមួយច្បាស់លាស់ពីខាងម្ចាស់ជំនួយធ្វើយ៉ាងណាដើម្បីបង្កើននូវកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងសង្គមស៊ីវិលទាំងមូល ។ បច្ចុប្បន្ននេះលោកកំពុងតែរៀបចំនូវឯកសារគោលដើម្បីនឹងត្រួសត្រាយថាយន្តការពង្រឹងសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងសង្គមស៊ីវិល ហើយ ខប់សែល បានចូលរួមផ្តល់ជាទីកន្លែងសហប្រតិបត្តិការ និងមានលក្ខណៈស្ថាប័នជាប្រចាំតែម្តង ទើបឃើញថាមានរបត់មួយដែលអាចពង្រឹងនូវកិច្ចសហប្រតិបត្តិការរវាងតួអង្គកម្ពុជាទាំងអស់ ហើយដែលមានការចូលចិត្តច្រើន គឺ ខប់សែល ធ្វើឡើងដោយដៃខ្មែរផ្ទាល់ ហើយធ្វើតាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់ខេត្តដែលមានការចូលរួមរបស់សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ថែមទៀត ។ ដូច្នេះម្ចាស់ជំនួយកំពុងតែរកកម្មវិធីដូចនេះព្រោះម្ចាស់ជំនួយទាំងនោះមិនមានតួនាទីផ្ទាល់នៅក្នុងកិច្ចការខ្មែរឡើយ តែមានសិទ្ធិលើការគ្រប់គ្រងការចាយវាយលុយកាក់ ។ ចំណែកសមត្ថភាព ធនធានមនុស្ស កំលាំងបញ្ញា បច្ចេកទេស ខ្មែរមានគ្រប់គ្រាន់ នៅតែឆន្ទៈនយោបាយនឹងធ្វើការជាមួយគ្នា ។ បច្ចុប្បន្នឆន្ទៈនយោបាយក៏យើងមានហើយដែរ ទាំងរាជរដ្ឋាភិបាល ទាំងសង្គមស៊ីវិល ជាពិសេសនៅក្នុងផ្នែកអភិវឌ្ឍផ្នែក ដូចជាសុខាភិបាល សិក្សាធិការក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ នៅតែផ្នែកមួយទេដែលជួបការពិបាកនៅឡើយគឺខាងសិទ្ធិមនុស្ស អភិបាលកិច្ច ។

នៅក្នុងរបៀបវារៈទី ៣ បញ្ហាចែកអំណោយ ខប់សែល ចង់ឈានទៅដល់កម្រិតមួយដែលអាចលើកជាសំណើនិងធ្វើការសង្កេតជូនដល់គណបក្សនយោបាយ រាជរដ្ឋាភិបាល និងតួអង្គទាំងអស់ ។ ខប់សែល យល់ថាជួនកាលមិនមែនជាការចោទប្រកាន់មិនមែនជាឆន្ទៈនយោបាយចង់ចែកអំណោយនៅពេលនោះទេ ប៉ុន្តែជួនកាលក៏មានដែរ ហើយជួនកាលការមិនយកចិត្តទុកដាក់ដោយគិតថាពេលណាដែលមានតម្រូវការរបស់ប្រជាពលរដ្ឋ ក៏ទៅចែកអំណោយពេលនោះ មិនបានយកចិត្តទុកដាក់ពីការជះឥទ្ធិពលទៅលើយន្តការ ការបោះឆ្នោត ជាពិសេសយុទ្ធនាការឃោសនាបោះឆ្នោត ។ ដូច្នេះ ខប់សែល ចង់លើកជាសំណើ ដូចដែលបានធ្វើនៅតាមខេត្តបើសិនជាមិនមានការទាក់ទងដល់អាយុជីវិតរបស់ប្រជាពលរដ្ឋ ដែលតម្រូវឱ្យរាជរដ្ឋាភិបាល ឬមួយអង្គការសង្គមស៊ីវិលដែលត្រូវតែយកអំណោយទៅចែកជូនដល់ប្រជាពលរដ្ឋភ្លាមគួរតែព្យួរទុកមួយរយៈ បើមិនដូច្នេះទេនាំឱ្យពិបាកដល់ គជប ។ មានអ្វីកើតឡើងក៏ត្រូវបន្ទោស គជប តែ គជប មិនគ្រប់គ្រងបានទេនៅក្នុងបញ្ហាចែកអំណោយនេះ ជាពិសេសនៅថ្នាក់ PEC CEC ។ ប្រធានបទមួយទៀត សកម្មភាពគណបក្សនយោបាយនៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោត បើពិនិត្យមើលថាតើបញ្ហាអ្វីដែលចេះតែនាំឱ្យប៉ះទង្គិចគ្នានៅក្នុងពេល ១៥ ឬ ៣០ ថ្ងៃរវាងគណបក្សនយោបាយ ហើយតើអាចបញ្ចៀសយ៉ាងម៉េចកុំឱ្យប៉ះគ្នា?

លោក **ម៉ារ សុផល** បានកត់សំគាល់ទាក់ទងនឹងសកម្មភាពចែកអំណោយ ដោយមិននិយាយដល់អំឡុងពេលឃោសនាបោះឆ្នោត គឺក្នុងដំណាក់កាលក្រោយ និងចន្លោះមុនការបោះឆ្នោតនីមួយៗ ។ ជាទូទៅសកម្មភាពចែកអំណោយមនុស្សធម៌មានច្រើនដោយសារតែប្រជាពលរដ្ឋមានភាពក្រីក្រជួបគ្រោះរាំងស្ងួត គ្រោះទឹកជំនន់ ខ្យល់ព្យុះផ្សេងៗ ការចែកអំណោចលើសកម្មភាពនេះល្អដើម្បីជួយសង្គ្រោះជនរងគ្រោះ ។ ប៉ុន្តែបើសង្កេតឃើញសកម្មភាពមួយចំនួនទៀតដែលប្រជាពលរដ្ឋមិនបានជួបគ្រោះធម្មជាតិ ឬ គ្រោះថ្នាក់អ្វីទេ តែមានសកម្មភាពចែកអំណោយក្នុងពេលនោះក៏មានពាក្យពេចន៍ខ្លះបានបង្កប់នូវខ្លឹមសារប្រសិនបើសង្កេតមើលខ្លឹមសារមានបង្កប់ន័យឃោសនាបោះឆ្នោត ។ ទាក់ទងនឹងច្បាប់បទបញ្ជានីតិវិធីនៃការបោះឆ្នោត គជប បានឆ្លើយហើយថា សមត្ថកិច្ចរបស់ គជប មានត្រឹមតែក្នុងអំឡុងពេលឃោសនាបោះឆ្នោតទេ នៅក្រៅអំឡុងពេលនេះមិនមានសមត្ថកិច្ចអ្វីទៅដោះស្រាយទប់ស្កាត់អ្វីបានទេ ។ ពាក់ព័ន្ធបញ្ហានេះនៅពេលដែលសកម្មភាពចែកអំណោយរបស់ថ្នាក់ដឹកនាំរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន តំណាងរាស្ត្រមកពីគណបក្សនយោបាយពេលខ្លះមានការយល់ច្រឡំក្នុងសកម្មភាពចែកអំណោយ ។ ដូចជាតំណាងរាស្ត្រមួយរូបមានតួនាទីនៅក្នុងរាជរដ្ឋាភិបាលផងជាតំណាងរាស្ត្រផង នៅពេលចុះទៅចែកពេលខ្លះមានឃើញអ្នកពាក់អាវគណបក្ស ហើយធ្វើសកម្មភាពចែកអំណោយក្នុងពិធី

សម្តោធសមិទ្ធផលជាដើម ។ លោកបានលើកជាគំនិតមួយថា ដើម្បីឱ្យ គជប ឬសង្គមស៊ីវិលទាំងអស់រៀបចំនូវសេចក្តីព្រាងច្បាប់មួយ ឬមួយបទបញ្ញត្តិនីតិវិធីមួយដើម្បីនឹងទប់ស្កាត់នូវសកម្មភាពឆ្លៀតឱកាសរបស់គណបក្សនយោបាយមួយចំនួន ដែលមានធនធានក្នុងការធ្វើសកម្មភាពក្រោយ និងចន្លោះពេលបោះឆ្នោតនីមួយៗ ធ្វើការទប់ស្កាត់សកម្មភាព ដើម្បីឱ្យមានភាពយុត្តិធម៌ដល់គណបក្សតូចៗផ្សេងទៀតដែលចង់ចូលរួមក្នុងការបោះឆ្នោតនេះផងដែរ ។ ចង់ឱ្យច្បាប់ចែងឱ្យ គជប មានសមត្ថកិច្ចមិនត្រឹមតែក្នុងអំឡុងពេលឃោសនាបោះឆ្នោតទេ សូម្បីតែក្រោយប្រកាសលទ្ធផលរហូតដល់មុនការបោះឆ្នោតមួយទៀត គជប គួរតែមានសមត្ថកិច្ចក្នុងការទទួលនូវពាក្យបណ្តឹងដើម្បីដោះស្រាយបញ្ហាដែលមានគណបក្សឆ្លៀតឱកាសធ្វើការឃោសនាចំៗតែម្តង ព្រោះ គជប ទោះបីជាចប់ការបោះឆ្នោតនីមួយៗក៏នៅមានលេខាធិការដ្ឋានកាន់ការទទួលបន្ទុកការងាររដ្ឋបាលជាប្រចាំ ។

លោក **ឱក សេរី សោភ័ក្តិ** ការចែកអំណោយនៅក្រៅយុទ្ធនាការឃោសនាបោះឆ្នោត នៅស្រុកណាក៏មានដែរ ព្រោះជាសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋចង់ឱ្យទៅអ្នកណាក៏បានដែរ មិនអាចឃាត់ឃាំងបានទេ ។ កាលណាមានភាពចាស់ទុំគេមិននិយាយភ្ជាប់ទៅក្នុងរឿងនយោបាយ គ្រាន់តែដឹងថាហ្នឹងជាសមាជិករបស់គណបក្ស ។ ដូច្នេះនៅក្នុងចន្លោះពេលបោះឆ្នោតហាមមិនបានទេព្រោះនេះជាសិទ្ធិ ដែលធានាដោយរដ្ឋធម្មនុញ្ញ ។ គជប បើសិនជានៅចន្លោះពេលបោះឆ្នោតក្នុងពេល ៥ ឆ្នាំមានឥទ្ធិពលក្នុងការគ្រប់គ្រងការចែកអំណោយជាការល្អណាស់ប្រសិនបើអាចធ្វើបាន គ្រាន់តែមិនមានភាពប្រាកដនិយម ព្រោះគ្រាន់តែធ្វើក្នុងពេលយុទ្ធនាការមានការលំបាកខ្លាំង ។

ឯកឧត្តម **ទេព នីថា** បានចូលរួមមតិមួយចំនួនទាក់ទងនឹងការចែកអំណោយ ។ បញ្ហាខ្លះដែល គជប ធ្លាប់បានធ្វើនៅក្នុងតែរយៈពេលនៃការឃោសនាបោះឆ្នោតប៉ុណ្ណោះ ។ នៅក្នុងច្បាប់បោះឆ្នោតទាំងពីរដែលមានមកពុំបានសរសេរមាត្រាណាឱ្យចំហាមឃាត់ការចែកអំណោយពេលឃោសនាបោះឆ្នោតទេ តែក្នុងនីតិវិធីនៃការឃោសនាបោះឆ្នោតក្នុងក្រមសីលធម៌របស់គណបក្សនយោបាយ គជប មានហាមពីករណីចែកអំណោយក្នុងពេលឃោសនាបោះឆ្នោតដែលមានលក្ខណៈជាការទិញសន្លឹកឆ្នោត ទិញទឹកចិត្ត ។ ក្នុងការអនុវត្តន៍ជាក់ស្តែងពេលឃោសនាបោះឆ្នោតនីមួយៗ កើតមានទំនាស់ឡើង ការពិតពេលឃោសនាបោះឆ្នោតមានការចែកអំណោយទោះបីក្នុងរូបភាពតូចក៏ដោយធំក៏ដោយ មានការបង្កើតបញ្ហាថាមានចែកអំណោយ ហេតុអ្វីបានជាគណបក្សដឹងហើយ បេក្ខជនដឹងហើយនៅតែចែកដោយចេតនាឬអចេតនាក្តី? ឆ្លងកាត់ការបោះឆ្នោត ២-៣ មកមានការពិន័យព្រមាន ប្តឹងគ្នាគឺមានស្ទើរតែគ្រប់គណបក្សទោះបីរូបភាពតូចធំក្តីគឺមាន ។ បញ្ហានេះ គជប បានខិតខំប្រឹងប្រែងធ្វើណាស់ ទី១. ការផ្សព្វផ្សាយបទបញ្ញត្តិនីតិវិធីតាមការបណ្តុះបណ្តាល ។ ការផ្សព្វផ្សាយនេះក្នុងការអនុវត្តន៍ជាក់ស្តែងគឺនៅឃុំ CEC ជាអ្នកផ្សព្វផ្សាយជាអ្នកអនុវត្តក្នុងការឃោសនាជាក់ស្តែង ។ នៅមុនការឃោសនាមានកម្មវិធីឱ្យ CEC ផ្សព្វផ្សាយឱ្យគណបក្សដែលនៅឃុំសង្កាត់ ដើម្បីរៀបចំសកម្មភាពឃោសនា ផ្តល់នីតិវិធីឱ្យគាត់ ជូនក្រមសីលធម៌ ហើយប្រាប់គាត់ថាសកម្មភាពឃោសនារបស់គាត់ក្នុងរង្វង់ ឧទាហរណ៍ ១ ខែ ឬកន្លះខែឃោសនាគាត់មានសកម្មភាពអ្វីខ្លះក្នុងឃុំ ឱ្យគាត់ដាក់កម្មវិធីមកឃុំមុនដើម្បីឃុំសម្រួលកម្មវិធីកុំឱ្យប៉ះកន្លែងជាន់ពេលវេលាគ្នា ហើយហាមអ្វីគឺប្រាប់គាត់តាំងពីដើមទីក៏ប៉ុន្តែនៅតែមានបញ្ហា ។ បញ្ហាចែកមិនដាច់ពីគ្នារវាងគណបក្សធ្វើសកម្មភាពក្នុងពេលឃោសនាជួលមនុស្ស និងសកម្មជនរបស់គណបក្ស ។ ឧទាហរណ៍ គណបក្សមួយគាត់ហែរដោយជួលឡានជួលស៊ីក្លូ ជួលម៉ូតូឌុបហែរគាត់ឱ្យលុយ គាត់ជួលម៉េក្រូឱ្យលុយ នេះទៅជាការប្តឹងថាចែកអំណោយ ទិញទឹកចិត្តដែរ ។ បញ្ហានេះពិបាកចែកណាស់ អ្នកប្តឹងក៏មានភស្តុតាង អ្នកចែកលុយក៏មានភស្តុតាងហើយនេះជាការលំបាក ។ មូលដ្ឋានសំខាន់គឺមាននៅតែក្នុងឃុំសង្កាត់ទេដែលគណបក្សទាំងអស់គ្នាបានដឹង ហើយយោគយល់គ្នាក្នុងកម្រិតណាមួយដែលអាចយោគយល់បានទើបដោះស្រាយចេញ ។ ការឃោសនាកន្លងមកមានបញ្ហាអ្វី គជប កម្រិតឱ្យ

CEC ដោះស្រាយក្នុងកម្រិតសម្រុះសម្រួលមួយដែលអាចសម្រុះសម្រួលបានព្រោះមានលើសខ្វះទៅវិញទៅមក ។ ដូចជាឆ្នាំ ២០០៣ បោះឆ្នោតតំណាងរាស្ត្រ បេក្ខជនម្នាក់មកឈរនៅនឹងផ្លូវពេលបោះឆ្នោត ហើយអ្នកស្រុកនៅក្បែរផ្ទះគាត់ ២-៣ នាក់ហូបនំបញ្ចុករែក គាត់ចេញលុយឱ្យនំបញ្ចុក ១ ចាន ៥០០ រៀល ក៏ប្ដឹងដល់ គជប ដែរករណីគាត់ទៅចេញលុយឱ្យនៅថ្ងៃបោះឆ្នោតខុសហើយ ប៉ុន្តែបើគិតកម្រិតប៉ុណ្ណឹងបានប៉ុនណា ។ បញ្ហានេះអាចដោះស្រាយបាន អាស្រ័យសំខាន់លើចេតនាចង់ដោះស្រាយ ឬមិនចង់ដោះស្រាយរបស់អ្នកដែលមានទំនាស់ ។

ចំពោះពេលវេលានៃការហាមចែកអំណោយតាមច្បាប់ គជប គ្រប់គ្រងតែនៅក្នុងពេលឃោសនាបោះឆ្នោតនៅឆ្នាំ ២០០៣ គជបបានធ្វើការងារមួយចំហានទៀតនៅពេល គជប សម្រេចលើបញ្ជីបេក្ខជនហើយដឹងថាអ្នកណាជាប់ជាបេក្ខជនហើយ គណបក្សណាមានបញ្ជីបេក្ខជនហើយ ចាប់ពីពេលនោះមកហាមចែកអំណោយ មិនឱ្យធ្វើអ្វីដែលជាការឃោសនា ។ ដោយសហកាជាមួយនឹង UNDP គជប ចុះកិច្ចព្រមព្រៀងមួយរវាងគណបក្សផ្សេងៗដើម្បីដោះស្រាយបញ្ហានេះមួយកម្រិត និងបានបើកទូលាយរយៈពេលនៃការហាមឃាត់តែមិនអាចធំទូលាយបានទេ ។ គណបក្សនយោបាយស្រុកណាក៏ដោយក្រៅពីការហាមឃាត់នៅក្នុងច្បាប់ទាក់ទងនឹងការបោះឆ្នោត គណបក្សមានសិទ្ធិធ្វើសកម្មភាពទាំងអស់ស្របច្បាប់ដើម្បីអូសទាញទឹកចិត្តពង្រីកសកម្មភាពរបស់គណបក្ស ដូចនេះការចែកអំណោយ ការធ្វើសកម្មភាពកសាងកំលាំងគណបក្សជារឿងធម្មតា ទោះបីនៅផ្លូវសាធារណៈ នៅទីស្នាក់ការក៏ដោយ ។ ប្រទេសប្រជាធិបតេយ្យធ្វើក្នុងរូបភាពផ្សេងៗគ្នា ក្នុងប្រទេសជឿនលឿនមិនដើរចែកអំណោយ ព្រោះអ្នកស្រុកសុទ្ធតែមាន ។ ប្រទេសខ្លះនៅក្បែរៗខាងយើងក្រៅពីពេលបោះឆ្នោត គេឱ្យខ្ចីលុយមុនទៅអភិវឌ្ឍន៍ភូមិឃុំមិនខុសច្បាប់ទេ ហើយសងវិញឬមិនសងអាស្រ័យលើកិច្ចសន្យា ។ ដូច្នេះការចែកអំណោយនេះមានការលំបាក ហើយរូបភាពនៃការចែកអំណោយ ឬទិញសន្លឹកឆ្នោតនេះពិបាកចាប់ ។ ឧទាហរណ៍ ពេលឃោសនាបោះឆ្នោតនាំគ្រូពេទ្យមួយក្រុមទៅភូមិដើម្បីព្យាបាលអ្នកជម្ងឺក្នុងភូមិដោយចែកថ្នាំពេទ្យជាដើម គជប ទៅចាប់ម្ដេចនឹងកើតបើនេះជាសកម្មភាពមនុស្សធម៌ ។ មិនមានឃោសនាអ្វីទេ តែដឹងថាពេទ្យនេះជាក្រុមអ្នកណា ។ គជប គ្រាន់តែត្រួតពិនិត្យមើលថាតើសកម្មភាពភ្ជាប់នឹងការឃោសនាទេ? ថ្នាំពេទ្យមានអ្វីដែរ? ទៅនិយាយឃោសនារបៀបណា? គជប គ្រាន់តែប្រាប់ឱ្យប្រយ័ត្នកុំឱ្យមានបញ្ហាប្ដឹង ។ គជប បានដោះស្រាយប៉ុណ្ណឹង តែបើទៅចាប់សកម្មភាពរបស់គេមិនត្រូវ ហើយប្រជាពលរដ្ឋខឹងទៀត ។ គជប អនុវត្តកន្លងមកគឺ ទី១. ឱ្យគណបក្ស បេក្ខជន អ្នកធ្វើការបោះឆ្នោត អាជ្ញាធរទាំងអស់យល់ពីនីតិវិធីនៃការឃោសនាបោះឆ្នោតនៅក្នុងដំណាក់កាលនៃការឃោសនាបោះឆ្នោត ទី២. ខិតខំអនុវត្ត និងទី៣. គឺការដោះស្រាយជាក់ស្ដែងរបស់ គជប ព្រោះពេលឃោសនាបោះឆ្នោត CEC ប្រជុំមុនអំឡុងពេលឃោសនាបោះឆ្នោត និងប្រជុំតាមការចាំបាច់ដែលមានបញ្ហាត្រូវដោះស្រាយ ។

កន្លងមកមានតែការមិនយោគយល់គ្នាដែលពិបាកដោះស្រាយ ។ ឧទាហរណ៍ ២០០៣ គណបក្ស ពីរហែរក្បួនបញ្ច្រាសផ្លូវគ្នាតាមពិត CEC រៀបចំម៉ោងពេលត្រឹមត្រូវហើយប៉ុន្តែគណបក្សមួយហែរមកយឺតនាំឱ្យផ្លូវឆ្លងកាត់គ្រាន់តែសុំឱ្យគណបក្សមួយទៅសិនគណបក្សមួយនៅចាំសិនមិនបាន ហើយប្រជែងមកទាំងពីរនាំឱ្យស្ទះផ្លូវទាំងអស់ នាំឱ្យគណៈកម្មាធិការក្រុងចុះមកជួយសម្រួលហើយមិនចេញទៀតយកប៉ូលីសចរាចរមកសម្រួល ស្ដីឱ្យប៉ូលីសទៀត នៅពេលទូរស័ព្ទប្រាប់មេគណបក្សរៀងខ្លួនទើបបានដោះស្រាយចេញ ។ ករណីសកម្មជននេះមានការលំបាកគ្រប់គ្រង បើសិនជាក្នុងការហែរក្បួននីមួយៗនៃការឃោសនា ឬក្នុងការធ្វើសកម្មភាពគ្រប់គ្រងមិនច្បាស់លាស់ទេ នឹងធ្វើអ្វីមួយដែលមិនមែនឃោសនាដើម្បីគណបក្សតែនាំឱ្យបាត់សម្លេងរបស់គណបក្សវិញ ។ កាលណាមានអំពើហិង្សាក្នុងការឃោសនា ចោទមកដល់ការបោះឆ្នោតដែលមិនប្រក្រតីថាមានអំពើហិង្សា ការពិតរឿងជារឿងដែលបង្ការមុនបាន ទើបបានបង្ការមុន ហើយអាចដោះស្រាយបានតែខ្វះការយោគយល់ ។

អ្វីដែល គជប ចាប់អារម្មណ៍សម្រាប់ការបោះឆ្នោតឃុំនេះ ការឃោសនាភាគច្រើននៅនឹងឃុំសង្កាត់ទេ ហើយអ្នកឃោសនា និងអ្នកធ្វើសកម្មភាពសុទ្ធតែអ្នកស្គាល់គ្នាទាំងអស់ ទោះបីមានអ្នកស្គាល់គ្នាក៏ដោយ ក៏ប៉ុន្តែវិធានការសំខាន់ណាស់ព្រោះថាអ្នកស្គាល់គ្នានេះបើសិនមានទំនាស់ គឺក្លាយជាអ្នកមានទំនាស់ ដែលនៅជិតផ្ទះគ្នា ហើយមិនងាយដោះស្រាយជាមួយគ្នា ។ បញ្ហានេះដើម្បីធ្វើបាន មិនមែនតែ គជប ទេទាំងអាជ្ញាធរគណបក្សនយោបាយ ទាំងអង្គការក្រៅរដ្ឋាភិបាលត្រូវរួមគ្នា ព្រោះមូលដ្ឋាននៃការយល់ដឹងនៅមានកម្រិតនៅឡើយ ដូច្នេះទំនាស់នយោបាយ នៅក្នុងចង្កោមដែលការយល់ដឹងមានកម្រិតនោះអាចជាទំនាស់ស្រួចស្រាល់ ។

លោក **អ៊ិក គីមហាន** ប្រធាននាយកដ្ឋានសរុប នៃខុទ្ទកាល័យគណបក្សប្រជាជនកម្ពុជា បានចូលរួមមតិពីបញ្ហាចែកអំណោយក្នុងពេលយុទ្ធនាការឃោសនាបោះឆ្នោត ។ ផ្អែកតាមច្បាប់និងនីតិវិធីនៃការបោះឆ្នោត ច្បាប់ពុំបានចែងច្បាស់លាស់ ហើយក្នុងនីតិវិធីក៏មានចែងតែអំណោយ ក្នុងគោលបំណងទិញទឹកចិត្តអ្នកបោះឆ្នោតតែប៉ុណ្ណោះ ដែលនេះបានធ្វើឱ្យការអនុវត្តន៏កន្លងមកជួបការស្មុគស្មាញ ។ បញ្ហាមួយលោកគ្រាន់តែលើកយកមកដើម្បីធ្វើការពិចារណាទាំងអស់គ្នា បានជួបប្រទះនៅពេលបោះឆ្នោតឆ្នាំ ២០០៣ ។ បញ្ហានេះ គជប ក៏បានដឹងច្បាស់ដែរព្រោះមានការប្តឹងផ្តល់គ្នាតាំងពី CEC PEC រហូតដល់ គជប ទៀតដោយបើកសវនាការបញ្ចប់នៅត្រឹម គជប ។ មានការចោទថាចែកអំណោយក្នុងគោលបំណងទិញទឹកចិត្ត តែបញ្ហានេះមុនបោះឆ្នោតប្រហែលមួយថ្ងៃ ហើយរដូវនោះទឹកឡើងខ្លាំង ។ មានគណបក្សមួយចែកលុយគាត់ថាមិនមែនជាការទិញទឹកចិត្តរបស់សមាជិកគណបក្សទេ គឺចែកក្នុងគោលបំណងជួយឱ្យសមាជិករបស់គាត់រើផ្ទះពីកន្លែងលិចទឹក ចំនុចនេះមិនមានចែងនៅក្នុងច្បាប់ផង ច្បាប់ថាទិញទឹកចិត្តអ្នកបោះឆ្នោត តែនេះគឺឧបត្ថម្ភសមាជិកដែលជួបគ្រោះទឹកជំនន់ ។ ពេលប្តឹងគ្នាបញ្ហានេះមិនមានទោស ដូច្នេះច្បាប់ និងនីតិវិធីមិនទាន់បានច្បាស់លាស់ដែរ ។ ដូច្នេះតើគួរធ្វើយ៉ាងម៉េចឬមួយនេះជាបញ្ហាមួយគួរយោគយល់គ្នា? បញ្ហានេះមានទាំងអស់គ្នា មិនមែនមានតែគណបក្សប្រជាជនកម្ពុជា ឬគណបក្សហ៊្វុនស៊ិនប៉ិច គណបក្សសមរង្ស៊ី ឬគណបក្សផ្សេងៗទៀតដែលចូលរួមបោះឆ្នោត ដល់ពេលប្រកាសលទ្ធផលមានចាញ់មានឈ្នះចេះតែចោទដាក់គ្នា ។ ការដែលធ្វើបានដោយសារតែច្បាប់ និងនីតិវិធីនៅចន្លោះប្រហោង ។ ដូចនេះគួរិះរកវិធានការយ៉ាងម៉េច? ឱ្យកម្រិតរឿងអំណោយទំហំប៉ុន្មាន?

លោក **ឱក សេរី សោភក្តិ៍** បានលើកថាទោះបីជាប្រទេសណាក៏ដោយការបោះឆ្នោតជាយន្តការមិនអាចបោះឆ្នោតមួយរកដំណោះស្រាយបានឃើញភ្លាមទេ ។ តែក្នុងរឿងចែកអំណោយនេះ គជប គួរតែមាននាយកដ្ឋានណាមួយ ដើម្បីធ្វើការចងក្រងឯកសារបទពិសោធន៏ ឧបទ្ទវហេតុ ឬអ្វីផ្សេងៗដែលទាក់ទងទៅនឹងលក្ខណៈនៃការចែកអំណោយណាទោះតូចធំយ៉ាងណាក៏ដោយតែត្រូវយកមករៀបទាំងអស់រៀបថាតើលក្ខណៈណាដែលឈានទៅរកបញ្ហានៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោត ។ ឯកសារនេះសំខាន់ដើម្បីឆ្លុះបញ្ចាំងពីមួយឆ្នាំទៅមួយឆ្នាំពីយន្តការមួយទៅយន្តការមួយ ។ ការរក្សាទុកឯកសារទាំងអស់នេះនៅបរទេសបានធ្វើ ដល់ពេលយូរៗម្តងទើបតម្រឹមច្បាប់នោះទៅតាមបទពិសោធន៏នៃការរកឃើញទើបបានមានការជឿនលឿនទៅមុខទៀត ព្រោះអ្នកនយោបាយមានគំនិតប្លែកៗ ដែលមិនអាចតាមទាន់ឡើយ ។ មានចំនុចខ្លះគួរតែយោគយល់ផងថារឿងតូចតាចដែលមិនអាចប្តូរលទ្ធផលបោះឆ្នោត តែដល់ពេលមកកសាងជាឯកសារសំរាប់តវ៉ាហាក់ដូចជាធំសម្បើមណាស់ ។ បញ្ហាពេលវេលានៃយុទ្ធនាការឃោសនា អ្នកណាយកជំនួយទៅចែកក្នុងពេលនោះមិនបញ្ហាទេ តែរឿងដែលបញ្ហាដែលឯកឧត្តម អ៊ុក ភូរិ លើកឡើងកាលពីឧបសែលខមលើកទី៨ ប្រសិនបើគណបក្សប្រជាជនធ្វើផ្លូវ ឬសង់អ្វីនៅកន្លែងមិនមានបញ្ហា តែបើគណបក្សផ្សេងទៅធ្វើមិនបានទេ អាជ្ញាធរហាមថាធ្វើមិនបានទេ នេះហើយជាការរើសអើងដែលមានលក្ខណៈជានយោបាយ ។ គណបក្សប្រជាជនកម្ពុជាមិនបានបញ្ចេទៅទេ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានមានប្រសាសន៏ទៀត “អ្នកណាក៏ដោយឱ្យតែទៅជួយប្រជាពលរដ្ឋជួយបានទាំងអស់” ប៉ុន្តែអាជ្ញាធរដែនដីនៅកន្លែងខ្លះ

អនុវត្តបទបញ្ជាខ្លះតឹងរឹងពេកឱ្យតែអ្នកដទៃចូលមកកន្លែងគឺមិនបានតែគណបក្សមួយទេជាការខុស ។ គ្រប់គ្នាតោងតែទទួលស្គាល់ ហើយតោងតែអប់រំតំណាងអាជ្ញាធរដែនដីឱ្យយល់ថាកន្លែងណាដែលគួរធ្វើ ។ បើចង់ជួយគណបក្សកាន់អំណាច តែធ្វើដូចនេះមានន័យថាធ្វើឱ្យគេស្អប់ ហើយលទ្ធផលនឹងបានផ្ទុយមកវិញ ។ ឧបសែលប្រ៊ែម ចុះទៅខេត្តសហប្រតិបត្តិការជាមួយចៅហ្វាយខេត្ត ចៅហ្វាយស្រុក និងក្រុមប្រឹក្សាឃុំសង្កាត់ល្អណាស់ ហើយមានកន្លែងខ្លះគាត់ធ្វើទាំងមិនដឹង គាត់ធ្លាប់តែធ្វើមក នៅធ្វើបន្តមកទៀតទៅ ។

លោក **ស៊ិន សំបូរ** ប្រធានការិយាល័យពិនិត្យច្បាប់ រដ្ឋសភា បានលើកថាពាក់ព័ន្ធនឹងបញ្ហាចែកមិនដាច់រវាងបញ្ហាការចែកអំណោយ ដោយសារតែមានទិដ្ឋភាពពីរផ្សេងគ្នាទី១. ទិដ្ឋភាពសង្គម ប្រពៃណីទំនៀមទំលាប់ ទី២. ទិដ្ឋភាពផ្លូវច្បាប់ ។

អំពីទិដ្ឋភាពសង្គម យើងមើលទៅរូបភាពនៃការផ្តល់ឱ្យនំបញ្ចុកមួយចានតម្លៃតែ ៥០០ ក្តីរហូតដល់តម្លៃតែ ១០០ ក្តីនោះមិនមែនជាបញ្ហាទេ ដោយសារតែការមើលឃើញមានរូបភាពតូច ។ រូបភាពខ្លះទៀត ឃើញថាវាជាទិដ្ឋភាពសង្គមដែលគួរតែមានការយោគយល់គ្នាជារឿងចាំបាច់ បើមិនមានការយោគយល់គ្នាទេ រឿងតូចក៏អាចបង្កទៅជារឿងធំបាន រឿងដែលមិនសមទៅជាសម រឿងដែលមិនមែនជាកិច្ចការបរិហាកេរ្តិ៍ទៅជាបរិហាកេរ្តិ៍ ។ ទិដ្ឋភាពមួយទៀតគឺទិដ្ឋភាពផ្លូវច្បាប់ ជាទិដ្ឋភាពដាច់ណាត់ដែលមិនអាចមានការយោគយល់ សូម្បីតែបន្តិចបន្តួចក៏មិនមានដែរ គឺជាវិធានការម៉ឺងម៉ាត់ ដែលមិនអាចឱ្យមានការយោគយល់ បើខុសត្រូវមានទោស ។ ចំពោះរូបភាពចែកអំណោយ និងទិដ្ឋភាពអំពើរពុករលួយ ទិដ្ឋភាពទាំងពីរនេះ បើនិយាយអំពីការចែកអំណោយក្នុងអំឡុងពេលនៃការបោះឆ្នោតពិបាកចែកឱ្យដាច់ថាអ្វីទៅ ដែលហៅថាចែកអំណោយក្នុងការហាមប្រាមរបស់ច្បាប់ អ្វីទៅដែលហៅថាជំនួយមនុស្សធម៌ជាទំលាប់របស់ប្រជាជនខ្មែរដែលតែងតែជួយគ្នាទៅវិញទៅមកនោះ? ប៉ុន្តែបើយកមកដាក់នៅលើជញ្ជីងដែលម្ខាងជាការចែកអំណោយ ម្ខាងទៀតជានិយមន័យនៃអំពើពុករលួយនោះទើបអាចដឹងថាអាចរកចំណុចរួមមួយបាន មាននិយមន័យច្បាស់លាស់ ។ ឧទាហរណ៍ នៅក្នុងប្រទេសអាល្លឺម៉ង់ដែលត្រូវបានចាត់ទុកថាជាអំពើរពុករលួយ រហូតដល់សូម្បីតែរបស់តូចមួយដុល្លា ក៏ចាត់ទុកថាជាអំពើរពុករលួយដែរ ហេតុអ្វី? អញ្ចឹងមានន័យថាប្រទេសអាល្លឺម៉ង់ជាប្រទេសគ្មានមនោសញ្ចេតនាសោះឬយ៉ាងម៉េច? ប្រទេសអាល្លឺម៉ងហាមផ្តាច់ថាបើសិនបើជាអំពើរមួយដែលផ្តល់តិចតួចនេះ អាចបង្កទៅជាបញ្ហាធំបានរហូតដល់ថ្នាក់គ្រូបង្រៀន ក្រោយពីកូនសិស្សឡើងពីថ្នាក់របស់ខ្លួនទៅថ្នាក់ផ្សេងបាត់ហើយ ឆ្នាំក្រោយមកទៀតឪពុកម្តាយរបស់កូនសិស្សដែលរៀនពីឆ្នាំមុននឹកឃើញគាត់យករបស់តិចតួចមកឱ្យគ្រូក៏មិនបានដែរ ព្រោះចំណុចនេះបង្កឱ្យមានបញ្ហាអំពើពុករលួយ គ្រូដែលបង្រៀនកូនសិស្សឆ្នាំនេះសង្ឃឹមថាផលប្រយោជន៍នឹងបាននៅឆ្នាំក្រោយ ឬឆ្នាំក្រោយមួយទៀត។ ដូចនេះអាចមានការរើសអើងកូនសិស្សនៅថ្នាក់ ។ បើលើកនៅក្នុងទិដ្ឋភាពសង្គមខ្មែរ ចំនុចនេះមានលក្ខណៈព្រៃផ្សៃមែនទែន សូម្បីតែនំបញ្ចុកមួយចានក៏អាចចោទគ្នាបានដែរ ប៉ុន្តែបើគិតមើលទិដ្ឋភាពផ្លូវច្បាប់មិនពិបាកដោះស្រាយទេ អ្វីបន្តិចបន្តួចឡើងទៅគឺច្បាប់មិនអនុញ្ញាតដាច់ខាត ប្រសិនបើច្បាប់កំណត់ថា ២ បូក ២ ត្រូវតែ ៤ ដូច្នេះគ្មាន ៤ កន្លះ ឬ៤ បន្តិចទេ ។ បើធ្វើសេចក្តីព្រាងច្បាប់ស្តីអំពីយន្តការ និងនីតិវិធីរៀបចំការបោះឆ្នោតយ៉ាងម៉េចផ្តល់ឱ្យសង្គមស៊ីវិល ឬសាធារណៈមតិបានចូលរួមច្រើន ហើយឱ្យមានពេលវេលាបានគ្រប់គ្រាន់នោះប្រហែលជាមានយោបល់ល្អៗជាច្រើនទៀតដែលជួយផ្តល់តែរឿងយកមិនយកជារឿងរបស់អ្នកផ្តើមសេចក្តីព្រាង។

លោក **ឱក សេរី សោភក្តិ** បន្ថែមថាក្នុងរឿងចែកអំណោយនេះបើឈានទៅដល់លក្ខណៈមួយអាចគ្រប់គ្រងបានគួតែចែកគ្នាទៅដរាបណាជំនួយមានលក្ខណៈទ្រង់ទ្រាយធំ តែបើគ្មានស្ថានការណ៍ណាជំរុញឱ្យប៉ះពាល់ដល់អាយុជីវិតរបស់ប្រជាពលរដ្ឋដោយសារគ្រោះមហន្តរាយ រាំងស្ងួត ឬទឹកជំនន់ទេ គជប គួរតែសុំហាមមិនឱ្យមានជំនួយទេ ព្រោះមានលក្ខណៈទ្រង់ទ្រាយធំត្រូវតែគ្រប់គ្រងឱ្យបាននៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោត ។ ច្បាប់ និងនីតិវិធីមានចែងអ្វីខ្លះដែលមិនត្រូវមាន ត្រូវគ្រប់គ្រងឱ្យបាន ប៉ុន្តែចំណុចតូច

តាច គួរតែយោគយល់គ្នា ព្រោះបើចង់គ្រប់គ្រងបញ្ហានេះក៏មិនអាចគ្រប់គ្រងបានដែរ ។ នៅពេលខប់សែលប្រ៊មនៅថ្នាក់ខេត្តចុះទៅធ្វើបានដឹងថានៅក្នុងសសៃរបស់សហគមន៍ខ្មែរតែម្តង ការដែលញ៉ាំអ្វីចូលទៅនិយាយជាមួយគ្នា កាហ្វេទឹកកកមួយកែវ នំបញ្ចុកមួយចានជាទំលាប់ ហើយដែលមើលទៅអត់មានជះឥទ្ធិពលទៅលើការបោះឆ្នោតទេ ។

លោក **មាស សុភា** ជំនួយការកម្មវិធី - មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ បានចាប់អារម្មណ៍ថាបញ្ហាចែកអំណោយនេះគឺខ្លាចប្រជាពលរដ្ឋយល់ច្រឡំការឃោសនាក្នុងពេលចែកអំណោយ ។ លោកលើកជាគំនិតមួយថា បើឱ្យគណបក្សនយោបាយមានសិទ្ធិចែកអំណោយក្នុងពេលឃោសនាបោះឆ្នោត ប៉ុន្តែខាង គជប ត្រូវបង្កើតយន្តការមួយដើម្បីផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យយល់ដឹងថាតើការដែលគណបក្សនីមួយៗចុះទៅឃោសនាបោះឆ្នោត តើប្រជាពលរដ្ឋគួរតែយកតម្លៃនៃអំណោយជាធំ ឬយ៉ាងម៉េច? អាចផ្សព្វផ្សាយតាមប្រព័ន្ធវិទ្យុ ទូរទស្សន៍ដើម្បីឱ្យប្រជាពលរដ្ឋយល់ឱ្យបានច្បាស់អំពីសិទ្ធិនិងតម្លៃសន្លឹកឆ្នោតរបស់ខ្លួន កុំឱ្យយកតម្លៃនៃអំណោយក្នុងពេលបោះឆ្នោតជាធំ ។ ប្រសិនបើអាចធ្វើដូចនេះបានប្រជាពលរដ្ឋនឹងអាចយល់អំពីតម្លៃសន្លឹកឆ្នោត របស់ខ្លួនថាមានតម្លៃយ៉ាងណាមិនអាចប្រៀបធៀបជាមួយអំណោយទាំងនោះបានទេ ។ ឬត្រូវបង្កើតក្រុមការងារមួយទៀតដែលធ្វើការជាមួយក្រុមចុះឈ្មោះដើម្បីផ្សព្វផ្សាយរឿងនេះឱ្យប្រជាពលរដ្ឋដឹងភ្លាមៗតែម្តង ។ ទាក់ទងប្រជាពលរដ្ឋណាដែលអាចមកចុះឈ្មោះបាន អាចផ្សព្វផ្សាយឬក៏មានវិធីសាស្ត្រច្រើន ។ បើធ្វើបែបនេះបានចំណេញដល់ប្រជាពលរដ្ឋបានទទួលអំណោយគ្រាន់តែទទួល តែក្នុងចិត្តដឹងថាទង្វើរបស់គណបក្សណាដែលអាចនឹងទទួលយកបាននិងមិនទទួលយកបាន ។

លោក **ឱក សេរី សោភក្តិ** បំភ្លឺថានៅភ្នំពេញកន្លែងដែលវិទ្យុ ទូរទស្សន៍ កាសែតទៅដល់អត់បញ្ហា ប៉ុន្តែនៅតំបន់ដាច់ស្រយាលតាមខេត្តនៅមានជីវភាពទាប ហើយជួនកាលការផ្សព្វផ្សាយទៅអត់ដល់ទេ ។ ចំពោះយើង ២០០-៣០០ រៀលមិនមានតម្លៃប៉ុន្មានទេ តែចំពោះគាត់ក្នុងពេលនេះច្បាស់ទទួលសិន ។ ពេលទទួលសិនប្រជាពលរដ្ឋឱ្យតែទទួលអ្វីពីគេគាត់យល់ថាជំពាក់គេហើយទឹកចិត្តគាត់គឺអញ្ចឹង កុំថាដល់ទៅ ៤០០០-៥០០០ ជួនកាហ្វេគាត់មួយកែវថ្ងៃក្រោយត្រឡប់មកវិញគាត់រត់មកចាប់ឱបថើប មិនធម្មតាទេកម្រិតជីវភាពនឹងការដែលធ្វើ ហើយបើសិនជាអនុញ្ញាតឱ្យគណបក្សនយោបាយធ្វើមានទ្រង់ទ្រាយធំ ហើយទៅឃោសនាប្រាប់គាត់ថាទទួល ចុះតែកុំឱ្យមនសិការបោះឆ្នោតឈរនៅលើលុយ គជប កាន់តែលំបាកមែនទែន ។

លោក **ផាន់ សុធា** អ្នកសម្របសម្រួលជាតិ នៃគំរោងគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ VBNK បានចូលរួមមតិទាក់ទងនឹងការហាមផ្តល់ និងទទួលរបស់របរបន្តិចបន្តួច ហាក់ដូចជាតឹងរឹងពេក ដោយមិនពិចារណាអំពីទំនាក់ទំនងក្នុងសង្គមកម្ពុជា ហើយដែលអាចនាំឱ្យប៉ះពាល់ដល់វប្បធម៌ប្រពៃណីរបស់ប្រជាពលរដ្ឋ ព្រោះឥឡូវនេះយើងកំពុងតែស្តារឡើងវិញ ។ ឧទាហរណ៍ ពីដើមបើអ្នកឈប់រទេះគោនៅក្បែរភូមិអ្នកស្រុកណាមួយ មានអ្នកស្រុកហុចសម្លរ បាយ បច្ចុប្បន្នមិនមានទេ ផ្ទុយទៅវិញបើឈប់ផ្តេសផ្តាសគេប្តឹង ។ ពីដើមដើរហត់តាមផ្លូវមានទឹកដាក់មុខផ្ទះចែកគ្នាហូប ឥឡូវមិនហានទេខ្លាចពុល ។ យើងកំពុងតែចង់ឱ្យអ្វីដែលល្អទាំងអស់នេះត្រឡប់មកវិញ ។ ចុះបើហាមការខ្ចីខ្ចីម ជី ហុចនំបញ្ចុកគ្នាមួយចាន លក្ខណៈល្អូកល្អឺន លក្ខណៈសាមគ្គីភាពក្នុងសង្គមកាន់តែរលត់មែនទែន ។ គួរគិតថាត្រូវការពារទប់ស្កាត់យ៉ាងម៉េច ពីរឿងសូកប៉ាន់ តែកុំគិតដល់រឿងគ្រោះថ្នាក់ដោយសារតែរឿងល្អូកល្អឺនសាមគ្គីភាពក្នុងសង្គមកុំឱ្យប៉ះពាល់បាត់បង់ដល់វប្បធម៌ជាតិ ។

លោក **អ៊ឹម សហវុឌ្ឍី** ប្រធានការិយាល័យឯកឧត្តម អ៊ឹង ហួត - គណបក្ស ហ៊្វុន ស៊ិនប៉ិច លើកឡើងថាបើនិយាយអំពីការចែកអំណោយត្រូវគិតពីសេរីភាព ធម្មតាការរស់នៅតែងតែមានសេរីភាព សិទ្ធិដើរហើរ សិទ្ធិនិយាយ សិទ្ធិចែកចាយ សិទ្ធិចែកអំណោយ.........។ បញ្ហានំបញ្ចុក ការចូលហាង ឬការដើរទៅជួបប្រជាពលរដ្ឋកំពុងមានការខ្វះខាត ឬមួយកំពុងឈឺតាមផ្លូវមានថ្នាំ

ជាប់ហោប៉ៅយើងឱ្យ គឺជាសេរីភាពនិងសិទ្ធិរបស់យើងក្នុងការឱ្យ ដែលមិនមានលក្ខណៈជាចែកអំណោយទេ ជាសិទ្ធិសេរីភាពរបស់បុគ្គលម្នាក់ៗ និងជាទំនៀមទំលាប់ខ្មែរពីដើមផង ។ តែលក្ខណៈជាការចែកអំណោយ គួរតែហាមនៅពេលយុទ្ធនាការបោះឆ្នោត ដូចជាការកោះហៅប្រជាពលរដ្ឋ ឬរកកន្លែងណាមួយធ្វើជាវេទិកា ឬចែកជាអំណោយតាមមេក្រូ ទើបមានលក្ខណៈមួយមិនអាចទទួលយកបានប៉ះពាល់ដល់ច្បាប់បោះឆ្នោត ។

លោក **ឱក សេរី សោភក្តិ៍** បានលើកឡើងខ្លឹមសាររួមពីរចំនុចដែលបានពិភាក្សានៅក្នុងកិច្ចប្រជុំនេះ: ទី១. បើការចែកអំណោយមិនទាក់ទងនឹងបញ្ហាសន្តិសុខស្បៀងបញ្ហាគ្រោះធម្មជាតិរបស់ប្រជាពលរដ្ឋទេការចែកអំណោយមនុស្សធម៌ដែលមានជាទ្រង់ទ្រាយធំ គួរតែកុំធ្វើអ្វីនៅក្នុងពេលយុទ្ធនាការឃោសនាបោះឆ្នោត ។ ការធ្វើជួបប្រជុំគ្នាមកទទួលអំណោយពីគណបក្សក៏ហៅថាចែកអំណោយដែរ ។ ទី២. ការជួយគ្នាទៅវិញទៅមក បញ្ហាសប្បុរសធម៌បន្តិចបន្តួចដែលមិនមានឥទ្ធិពលលើលទ្ធផលនៃការបោះឆ្នោតចាត់ទុកថាជាសន្តានចិត្ត ជាវប្បធម៌របស់ខ្មែរក្នុងសហគមន៍ក្នុងការជួយគ្នាទៅវិញទៅមក ។ កាលណាលើកបែបនេះអាចឱ្យមានតម្រូវការក្នុងការឱ្យនិយមន័យច្បាស់លាស់ថាចែកអំណោយដែលមានលក្ខណៈនយោបាយនៅក្នុងយុទ្ធនាការឃោសនា ត្រូវតែកំណត់និយមន័យឱ្យច្បាស់ ។ ដរាបណាមិនបានឱ្យនិយមន័យនិងឧទាហរណ៍ច្បាស់លាស់ទេ នាំឱ្យមានការលំបាកកាន់តែច្រើនឡើង ។ លក្ខណៈតូចតាចដូចជានំបញ្ចុកជាដើមគឺនៅក្នុងបរិបថកម្ពុជាសព្វថ្ងៃគួរតែអនុគ្រោះ ។ នៅប្រទេសថៃឈានទៅដល់កម្រិតមួយពេលដែល យុទ្ធនាការឃោសនាបោះឆ្នោត តំណាងរាស្ត្រទិញមាន់យកទៅឱ្យផ្ទះត្រូវហាមទិញទាំងអស់ ។ អ្នកតំណាងរាស្ត្រខ្លះមិនឱ្យលុយទេ តែ យកជ្រូក មេគោ ដើម្បីជួយប្រជាពលរដ្ឋ ប៉ុន្តែគណៈកម្មាធិការជាតិរបស់ថៃហាមឃាត់សកម្មភាពនេះ ដោយសំអាងថាការធ្វើនេះមានឥទ្ធិពលទៅលើការសម្រេចចិត្តបោះឆ្នោតរបស់ប្រជាពលរដ្ឋ ។

ឯកឧត្តម **ទេព នីថា** ចូលរួមជម្រាបជូនអង្គប្រជុំមួយចំនួនទៀតទាក់ទងនឹងបញ្ហាចែកអំណោយ ។ ជាទូទៅក្នុងពេលឃោសនាបោះឆ្នោតគឺមានហាមទាំងតូចទាំងធំ ។ បំណងជាចំបងក្នុងការលើកយកបញ្ហាតូចតាចគឺចង់បញ្ជាក់រឿង ដែលទាក់ទងនឹងការយោគយល់គ្នា ព្រោះអ្នកប្តឹងគឺគណបក្ស ហើយអ្នកត្រូវគេប្តឹងក៏គណបក្ស នេះជាបញ្ហារបស់គណបក្សនយោបាយ ដែលប្រកួតប្រជែងគ្នាក្នុងការបោះឆ្នោត ។ ឧទាហរណ៍ នំបញ្ចុកមួយចាន ឬមួយក៏ព្រលឹមឡើងជិះឡានមកបោះឆ្នោតជាមួយគ្នាម្នាក់ដឹងថាអ្នកនេះធ្វើការគណបក្ស ឬប្រកាន់ខាងគណបក្សទៅហូបគុយទាវជាមួយគ្នាចេញលុយឱ្យព្រោះពេលបោះឆ្នោតអ្នកណាមានមធ្យោបាយអាចមកជាមួយគ្នាបាន ជូនកាលមកទាំងក្រុមៗរួចចេញលុយគុយទាវក៏មានរឿងប្តឹងដែរ ។ អង្គប្រជុំបានលើកឡើងថា គួរអនុគ្រោះចំណុចតូចៗ តែជាទូទៅ គជប មិនអនុគ្រោះទេ ។ រឿងសំខាន់លើគណបក្សនយោបាយអ្នកប្តឹង ព្រោះតែកាលណាមានករណី គណបក្សមួយទៀតប្តឹងមក CEC ចាប់ផ្តើមដោះស្រាយ ។ ករណីនេះដោះស្រាយមិនងាយចេញទេ មានតែហៅមកសម្រុះសម្រួល បើក្នុងករណីសម្រុះសម្រួលគ្នាបានក៏សម្រុះសម្រួល ។ ការងារនេះអាចដោះស្រាយបានអាស្រ័យលើឆន្ទៈនៃការយោគយល់គ្នា តែក្នុងកម្រិតដែលអាចដោះស្រាយបាន ក្នុងករណីដែលធំដុំដូចជាដាក់មេក្រូចែកអំណោយគឺខុសច្បាប់ទាំងស្រុង ។

ករណីមួយទៀតចែកនៅក្នុងសកម្មជនគណបក្សក៏មានករណីប្តឹង ។ ឥឡូវនេះ គជប មានពិសោធន៍ច្រើនក្នុងពេលបង្រៀនទោះបីឯកសារនេះអត់បានចងក្រងមែន តែក្នុងពេលបង្រៀននៅ ថ្នាក់ CEC គជប បានបញ្ជាក់រឿងនេះឱ្យយល់ ។ ឧទាហរណ៍ គណបក្សមួយធ្វើសកម្មភាពឃោសនាក្នុងឃុំ ដោយមានទីស្នាក់ការគណបក្ស អ្នកខ្លះមិនមានទីស្នាក់ការគាត់ទៅនៅកន្លែងណាមួយមួយក្រុម ហើយសកម្មជនត្រូវការហូបបាយ លុយជិះម៉ូតូឌុប ត្រូវការផ្សេងៗ ដូចនេះគណបក្សនោះចែកលុយឱ្យសកម្មជនរបស់

គាត់ក៏ប្តឹងដែរ ។ ចំនុចអាចដោះស្រាយបានគឺគណបក្សនៅមូលដ្ឋានធ្វើអ្វីមួយនៅពេលឃោសនាបោះឆ្នោតទាក់ទងការផ្តល់លុយកាក់ បើមិនលាក់បាំងទេ ត្រូវប្រាប់ត្រង់ទៅត្រង់មក CEC ថាថ្ងៃនេះប្រជុំសកម្មជន ត្រូវរៀបចំផែនការឃោសនា មិនមែនប្រាប់ទាំងអស់ ។

ជាទូទៅការចែកអំណោយពេលឃោសនាបោះឆ្នោត គជប ហាមទាំងអស់ ទោះបីរូបភាពណាក៏ដោយឱ្យតែមើលឃើញដឹងថាទាក់ទងនឹងការទិញទឹកចិត្ត ។ អាស្រ័យលើការយោគយល់គ្នារបស់គណបក្សធ្វើការឃោសនានៅមូលដ្ឋានទាំងអស់ ហើយដោះស្រាយជាមួយគ្នាបាន ។ ការបោះឆ្នោតកន្លងមកមាននៅឃុំខ្លះគណបក្សត្រូវគ្នា មិនប្តឹងគ្នាធ្វើអ្វីចែកគ្នាធ្វើទាំងអស់គ្នា ឯអ្នកសង្កេតការណ៍ប្តឹងវិញម្តង ។ រឿងប្លែកៗកើតមានច្រើនណាស់ ក្នុងពេលឃោសនាបោះឆ្នោត ។

លោក **ម៉ារ សុផល** បានបង្ហាញជូនអង្គប្រជុំទាក់ទងនឹងបញ្ហាសង្កេតក្នុងយុទ្ធនាការឃោសនាបោះឆ្នោត ខុមហ្វ្រែលបានរៀបចំជាគម្រោងសាកល្បងមួយទាក់ទងនឹងការសង្កេតទៅលើការចំណូល ចំណាយរបស់គណបក្សនយោបាយ ពេលឃោសនាបោះឆ្នោត ។ ក្រោយពីបានចូលរួមវគ្គសិក្សារយៈពេលខ្លីមួយនៅប្រទេសឥណ្ឌូនេស៊ី ឃើញថាទទួលបានបទពិសោធន៍ពីខាងប្រទេសជិតខាង ក៏ដូចជាបណ្តាប្រទេសមួយចំនួននៅអឺរ៉ុប អាមេរិកឡាទីនទាក់ទងនឹងការសង្កេតការណ៍ចំណូល និងការចំណាយរបស់គណបក្សនយោបាយក្នុងពេលឃោសនាបោះឆ្នោត ។ បើពិនិត្យមើលច្បាប់របស់ប្រទេសកម្ពុជា ឃើញថាហិរញ្ញវត្ថុរបស់គណបក្សនយោបាយមិនទាន់បើកទូលាយផ្តល់លទ្ធភាពឱ្យសង្គមស៊ីវិលអាចទទួលបាននូវព័ត៌មានអំពីហិរញ្ញវត្ថុ គ្រាន់តែតម្រូវឱ្យគណបក្សនយោបាយរាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនទៅ គជប ។ តើ គជប អាចមានលទ្ធភាពសហការក្នុងកម្រិតណាចំពោះគម្រោងការងារនេះប្រសិនបើ ខុមហ្វ្រែលមានគម្រោងនឹងធ្វើការអង្កេតក្នុងការទទួលបានចំណូល និងចំណាយរបស់គណបក្សនយោបាយនីមួយៗក្នុងអំឡុងពេលឃោសនា ។ គោលបំណងសំខាន់ គឺចង់ឱ្យមានភាពយុត្តិធម៌រវាងគណបក្សនយោបាយទាំងអស់ដែលចូលរួមក្នុងការបោះឆ្នោតឱ្យបានដឹងទាំងអស់គ្នា ហើយអាចទទួលបានព័ត៌មានអំពីចំណាយ ចៀសវាងការនិយាយថាគណបក្សធំចំណាយច្រើនជាងគណបក្សតូចធ្វើឱ្យសកម្មភាពទាក់ទាញបាននូវសន្លឹកឆ្នោតមានភាពខុសគ្នា ។

ឯកឧត្តម **ទេព នីថា** បំភ្លឺថាថវិការបស់គណបក្សនយោបាយសម្រាប់ គជប ច្បាប់ផ្តល់អំណាចឱ្យទាក់ទងនឹងថវិកានៃការឃោសនានេះ មានចែងក្នុងច្បាប់បោះឆ្នោត ប៉ុន្តែថវិកាទូទៅរបស់គណបក្សនយោបាយគឺមាននៅក្នុងច្បាប់ស្តីពីគណបក្សនយោបាយដែលនោះជារបាយការណ៍របស់គណបក្សដែលត្រូវរាយការណ៍ទៅក្រសួងមហាផ្ទៃ ដែលបញ្ហាពីរខុសគ្នា ។ កន្លងមក គជប មិនដែលបានត្រួតពិនិត្យទេ គ្រាន់តែការគ្រប់គ្រងបញ្ហាចំណាយរបស់គណបក្ស គឺក្នុងពេលឃោសនាបោះឆ្នោត ពេលបោះឆ្នោត គណបក្សត្រូវឱ្យលេខគណនីមក គជប ហើយចំណូលចំណាយប៉ុន្មានប្រសិនបើចាំបាច់ គជប នឹងត្រួតពិនិត្យ ។ រហូតមកដល់ឥឡូវពុំដែលមានបញ្ហារឿងថវិកាអ្វីទេ គជប មិនដែលទារ ឬក៏ត្រួតពិនិត្យឯកសារនេះទេ ។ ការចំណាយរបស់គណបក្ស ទី១. ច្បាប់មិនមានកម្រិតថាបេក្ខជនម្នាក់ត្រូវចំណាយប៉ុន្មាន ប្រទេសខ្លះមានកម្រិតតែម្តងសម្រាប់ការឃោសនារបស់បេក្ខជនមួយត្រូវចាយប៉ុនណា ហើយត្រួតពិនិត្យចំណាយដែលស្របច្បាប់ មានន័យថាបេក្ខជនត្រូវមានលេខគណនី ហើយចាយប៉ុន្មានអាចត្រួតពិនិត្យបាន តែការចាយក្រៅនៅតែចាប់មិនបាន ។ នៅកម្ពុជាច្បាប់មិនមានកំណត់ទេ ដូច្នេះបញ្ហាថវិកានេះ គជប មិនបានត្រួតពិនិត្យទេ ហើយក៏មិនដែលសុំរបាយការណ៍មកដែរ ។ ក្រោយពេលបោះឆ្នោត ២០០៣ គណបក្សប្រជាជនបានទូរស័ព្ទមកថា គជប យករបាយការណ៍ហិរញ្ញវត្ថុពេលបោះឆ្នោតរបស់គណបក្សទេ?

អំពីការចំណាយរបស់គណបក្សក្នុងការឃោសនា គជប មិនដឹងរកយុត្តិធម៌របៀបណារវាងគណបក្សធំ និងគណបក្សតូច? គណបក្សខ្លះពេលដែលឈរបោះឆ្នោតរកតែលុយ ១៥ លានរៀលទៅបង់ដើម្បីឈរឈ្មោះមិនមានទេ ។ គណបក្ស២-៣ ដែលមកដាក់

ឈ្មោះចុះបញ្ជីបេក្ខជនដែរ ហើយមិនមានលុយបង់ក៏ឈប់វិញទៅក៏ គជប អត់ទទួលទៅ ។ បើច្បាប់មិនកម្រិតចំនួនចាយលទ្ធភាពនៅតែខុសគ្នា គណបក្សមានលុយនៅតែធ្វើបានគ្រប់ផែនការ ឬលើសផែនការតាមរបៀបណាមួយ គណបក្សដែលមិនមានគ្រប់នៅតែមិនគ្រប់ ។ ការរកយុត្តិធម៌ក្នុងការចំណាយលុយនេះ បើច្បាប់កំណត់មកគ្រាន់តែបានកម្រិតក្នុងកម្រិតណាមួយតែបើសិនជាឱ្យចាយស្មើគ្នាធ្វើមិនកើតទេ ព្រោះការបោះឆ្នោតប្រកួតប្រជែងអំណាចនេះអាស្រ័យលើការសម្រេចរបស់ប្រជាពលរដ្ឋមែន ក៏ប៉ុន្តែអាស្រ័យលើថវិកា និងសកម្មភាពរបស់គណបក្សដែរ បើសិនជាមិនមានលុយសោះទៅធ្វើសកម្មភាពក៏ធ្វើអ្វីមិនចេញដែរ ។

លោក **ឱក សេរី សោភ័ក្តិ** បានបន្ថែមថានៅក្នុងរឿងការចំណាយរបស់គណបក្សនៅប្រទេសកម្ពុជាសព្វថ្ងៃទាក់ទងនឹងសង្គមទាំងមូល ហើយក្នុងសភាពការសព្វថ្ងៃពិបាកណាស់ ព្រោះកាលណានិយាយអំពីរឿងច្បាប់មានទិដ្ឋភាព ៣ យ៉ាងគឺ ទី១ តើការពង្រាងច្បាប់ ហើយអនុម័តច្បាប់ឱ្យឆ្លើយតបនឹងសភាពការណ៍របស់សង្គមនិងមានការចូលរួមអំពីគ្រប់ផ្នែកនៅក្នុងសង្គមដែរទេ? ទី២. ការអនុវត្តន៍ច្បាប់ដោយសាមីស្ថាប័នផ្ទាល់នៅក្នុងលក្ខណៈគ្រប់យ៉ាងទៅតាមច្បាប់ឬមួយនៅក្នុងលក្ខណៈប្រើច្បាប់ ដើម្បីផលប្រយោជន៍របស់ខ្លួន។ ទី៣. បើប្រើទៅហើយខុសច្បាប់តើអង្គការដែលសម្រាប់ដាក់ពិន័យមានលក្ខណៈយ៉ាងណាដែរ? ទិដ្ឋភាពទាំងនេះនៅមានស្រពិចស្រពិលណាស់នៅក្នុងសង្គមកម្ពុជា ដូចនេះបញ្ហាហិរញ្ញវត្ថុរបស់គណបក្សនៅក្នុងការបោះឆ្នោត គឺនៅមានសភាពងងឹតនិងពិបាកត្រួតត្រាទោះបីជា គជប មានក្រដាសច្បាប់នៅក្នុងដៃក៏នៅពិបាក ។ ប្រទេសឯទៀតៗដូចជាបារាំងជួបបញ្ហាដូចគ្នាដែរ ប៉ុន្តែសហគមន៍នីមួយៗ លើកបញ្ហាឡើងពេលលើកយូរៗទៅច្បាប់ចេះតែកែតម្រឹមតម្លាភាពក៏មានហូរហែររហូតមកដល់លក្ខណៈមួយដែលអាចទទួលយកបាន ប្រទេសកម្ពុជាត្រូវតែតស៊ូមតិច្រើនថែមទៀតទាល់តែពេលណាមួយដែលកម្រិតជីវភាពរបស់ប្រជាពលរដ្ឋអាចនឹងរស់ដោយខ្លួនឯងបាន អាចនឹងរស់នៅលើសតិសម្បជញ្ញៈបាន ទើបការបោះឆ្នោតមិនឈរនៅលើទឹកលុយ មិនឈរនៅលើការចែកអំណោយ ។

ឯកឧត្តម **ទេព នីថា** លើកឡើងបន្ថែមថាបើពិនិត្យមើលតាមការឃោសនាបោះឆ្នោតតាំងពីឆ្នាំ ១៩៩៨ មកមានបញ្ហាកើតមានក្នុងកម្រិតខុសៗគ្នាទាក់ទងនឹងសភាពការណ៍សង្គមនៅក្នុងដំណាក់កាលនៃការបោះឆ្នោត ។ ឧទាហរណ៍ ឆ្នាំ ១៩៩៨ ជាដំណាក់កាលមួយដែលក្តៅក្នុងការឃោសនាបោះឆ្នោត ការប្រកួតប្រជែងមានសភាពមួយដែលខ្លាំងក្លា ប្រកួតប្រជែងគ្នាខ្លាំងទាំងការឃោសនាទាំងរូបភាពផ្សេងទៀត តាំងពីការធ្វើសកម្មភាពដែលហាមឃាត់ ។ ឆ្នាំ ២០០២ ការឃោសនាមានកម្រិតល្អប្រសើរជាងឆ្នាំ ១៩៩៨ ព្រោះកម្រិតឃោសនានៅឃុំទាបជាងហើយមនុស្សតិចជាង រូបភាពមិនសូវធំដូច ១៩៩៨ ទេ ។ ការយល់ដឹងរបស់ប្រជាពលរដ្ឋក៏ដូចជាគណបក្សនយោបាយក៏មានកម្រិតយល់ដឹងលើការបោះឆ្នោត ពីសិទ្ធិសេរីភាពរបស់ខ្លួន សកម្មភាពនយោបាយរបស់ខ្លួនបានច្រើនជាង ។ មកឆ្នាំ ២០០៣ អំពើហិង្សាក្នុងការបោះឆ្នោតបានថយចុះគណបក្សក៏មានយល់ដឹងហើយប្រុងប្រយ័ត្នតំណាងគណបក្ស ឬសកម្មជនគណបក្សមានការយល់ដឹងពីតួនាទី និងភារកិច្ចរបស់ខ្លួនបានច្រើន។ ទំនាស់នៅក្នុងឆ្នាំឃោសនាបោះឆ្នោតពីដំណាក់កាលមួយទៅដំណាក់កាលមួយមានរូបភាពផ្សេងៗគ្នាដែលអាចវាយតម្លៃបានថាទាំងគណបក្សនយោបាយ ទាំងប្រជាពលរដ្ឋមានការយល់ដឹងច្រើន។ ឆ្នាំ ១៩៩៨ មានរឿងច្រើនដែលជាការទាញបញ្ចូលមករឿងនយោបាយទាំងអស់ ក្នុងពេលឃោសនាបោះឆ្នោត ឬពេលបោះឆ្នោតសំខាន់ក្នុងពេលឃោសនាបោះឆ្នោត។ ជិះម៉ូតូបុកគ្នាដួលស្លាប់សោះក៏ទាញមករឿងនយោបាយដែរ ហើយក្នុងមនុស្សម្នាក់ជួនកាលផែកក្នុងហោប៉ៅអាវទៅមានកាតគណបក្សពីរ ឬបីគណបក្សនីមួយៗទាញថាជារបស់ខ្លួន ហើយឱ្យ គជប ដោះស្រាយទាំងអស់ ។ មានរូបភាពផ្សេងទៀតគណបក្សដែលចូលរួមក្នុងការបោះឆ្នោតមួយចំនួនមាននិន្នាការធ្វើឱ្យការបោះឆ្នោតមានរូបភាពល្អ ហើយមួយក្រុមទៀតមាននិន្នការមួយធ្វើឱ្យការបោះឆ្នោតឃើញតែខ្មៅងងឹតតែម្តង។

ឆ្នាំ ២០០២ មានកម្រិតថយចុះ ហើយ NGOs បានដើរតួនាទីសំខាន់ដែរនៅមូលដ្ឋាន ទាំងបេក្ខជនដែលឡើងវេទិកាសេរីផ្សេងៗមានការយល់ដឹងពីតួនាទី ប្រជាពលរដ្ឋដែលចូលរួមក៏មានការយល់ដឹង ដោយសារទី១. តែប្រជាពលរដ្ឋបានទទួលការអប់រំផ្សព្វផ្សាយព័ត៌មានពី គជប ក៏ដូចជាពី NGOs និងអាជ្ញាធរ ទី២. មានពិសោធន៍ពីការបោះឆ្នោតមុនៗមក ។ ការយល់ច្បាប់កាន់តែបានច្រើនកាន់តែបន្ថយការយល់មិនត្រឹមត្រូវពីមុនមកសម្រាប់ការឃោសនាបោះឆ្នោតឬសម្រាប់សកម្មភាពនយោបាយ ។ គាត់ត្រូវធ្វើឱ្យបានត្រឹមត្រូវជាងមុន ហើយអ្វីដែលមិនច្បាស់លាស់គាត់សួរ ។ ឆ្នាំ ២០០៣ មានភាពល្អប្រសើរបានមួយកម្រិត ការឃោសនារបស់គណបក្សនីមួយៗ ទោះបីមានការលើសលួសពាក្យពេជន៍ខ្លះក្តីប៉ុន្តែពេលដែល គជប ហៅប្រព័ន្ធផ្សព្វផ្សាយមករំលឹកបញ្ហានេះ ម្នាក់ៗទទួលយល់ព្រម មានន័យថាពីឆ្នាំ ១៩៩៨ ពេលប្រព័ន្ធផ្សព្វផ្សាយផ្សាយអ្វីមួយ ពេលហៅមកប្រាប់មិនឆ្លើយថាខុសទេ ។ ការឃោសនាផ្ទាល់របស់បេក្ខជននៅមូលដ្ឋានដែលអាចបង្កទំនាស់តិចតួច និងងាយដោះស្រាយបាន តែអ្វីដែលពិបាកដោះស្រាយគឺនៅពេលប្រព័ន្ធផ្សព្វផ្សាយ ផ្សាយតាមរលកធាតុអាកាស ឬតាមរូបភាពឆ្លើយទៅឆ្លើយមក ។ សម្រាប់ការឃោសនាបោះឆ្នោតកន្លងមកអ្វីដែលបន្សល់ឱ្យនិងត្រូវធ្វើការប្រុងប្រយ័ត្ន និងរៀបចំដើម្បីដោះស្រាយថែមទៀតនោះគឺ :

ទី១. ការចែកអំណោយ ។ ពីការបោះឆ្នោតមួយទៅការបោះឆ្នោតមួយ ទោះបីតូច ឬធំ តិច ឬច្រើនមានជានិច្ច ។

ទី២. ទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងរដ្ឋទាំងឯកជន ។ ការផ្សព្វផ្សាយទាក់ទងនៅដំណាក់កាលណាឃោសនាបោះឆ្នោត និងដំណាក់កាលមិនឃោសនាបោះឆ្នោត សកម្មភាពរបស់គណបក្សនយោបាយ និងរបស់រដ្ឋាភិបាល។ រឿងនេះពិបាកបែងចែកគ្នាណាស់ បើក្នុងពេលឃោសនាបោះឆ្នោត គជប មានសិទ្ធិលើប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋដើម្បីកម្រិតសកម្មភាពនៃការផ្សព្វផ្សាយមួយចំនួន ប្រព័ន្ធឯកជនក៏មានការណែនាំរំលឹកពីបញ្ហានេះដែរតែក្នុងកម្រិតណាមួយ ។

បញ្ហាទំនាស់នៅពេលឃោសនាបោះឆ្នោត ទី១. ការចែកអំណោយ ទី២. ការប្រើប្រាស់ប្រព័ន្ធព័ត៌មាន ។ បញ្ហាទាំងអស់នេះ គជប បានរៀបចំវិធានការច្រើនណាស់ដោយផ្អែកលើមូលដ្ឋានច្បាប់ដែលមាន ដូចជា នីតិវិធី ក្រមសីលធម៌ ការផ្សព្វផ្សាយ ហើយពេលបោះឆ្នោតគឺយើងប្រជុំនៅថ្នាក់ជាតិក៏មាន ថ្នាក់ខេត្តក៏មាន ។ នៅថ្នាក់ខេត្ត និងនៅ គជប ឆ្នាំ ២០០៣ ប្រជុំរៀងរាល់សប្តាហ៍ ជាមួយគណបក្សនយោបាយ NGOs ដោយឡែកពីគ្នាពីប្រព័ន្ធផ្សព្វផ្សាយ ហើយជូនព័ត៌មានគ្នាទៅវិញទៅមក ក្នុងករណី ចាំបាច់ គជប អញ្ជើញមកជួបជុំនិយាយគ្នា ។ នៅខេត្តប្រជុំប្រចាំសប្តាហ៍ដូចគ្នាគឺចំរុះតែម្តងនិងនៅឃុំប្រជុំប្រចាំសប្តាហ៍ដូចគ្នា ហើយបើចាំបាច់ គឺហៅមកប្រជុំទៀតមិនគិតថាសប្តាហ៍ទេ ដើម្បីដោះស្រាយបញ្ហានៅនឹងមុខតែម្តង ។ គណបក្សនយោបាយចូលរួមដោយមានអាជ្ញាធរបោះឆ្នោត NGOs និងមានអាជ្ញាធរសន្តិសុខចូលរួមទៀត គឺទាញគំនិតក្នុងអង្គប្រជុំធ្វើយ៉ាងម៉េចឱ្យឃើញថាទោះបីគណបក្សមកប្រកួតប្រជែងក្នុងការបោះឆ្នោតក៏ដោយគឺការបោះឆ្នោតជាការបោះឆ្នោតរបស់ជាតិមួយទាំងមូល ទាំងអស់គ្នាត្រូវខំធ្វើឱ្យការបោះឆ្នោតប្រព្រឹត្តិទៅបានល្អ ការប្រកួតប្រជែងគ្នាដោយយុត្តិធម៌ គឺទាញអារម្មណ៍ឱ្យមកចំកន្លែងប្រមូលផ្តុំទើបរកដំណោះស្រាយ ។

ជាសរុបមកវិញបញ្ហាដែលនៅសល់អាចមានពីរ ទី១.អំណោយ ទី២.ប្រព័ន្ធផ្សព្វផ្សាយ ហើយបញ្ហាអំពើហិង្សាមានថយចុះដោយសារការងារសន្តិសុខ គជប តែងសហការជាមួយក្រសួងមហាផ្ទៃ ។ ការដោះស្រាយរបស់ គជប ទី១. ច្បាប់នីតិវិធី ទី២. ការអប់រំ ទី៣. ការអនុវត្តន៍ដោះស្រាយផ្ទាល់ដែលសុំឱ្យមានឈរលើការយោគយល់គ្នាមួយក្នុងផលប្រយោជន៍រួមមួយដើម្បីដោះស្រាយ។

លោក **ឱក សេរី សោភក្តិ** បានសង្ខេបខ្លឹមសារដែលបានពិភាក្សានៅព្រឹកនេះ:

**ទី១.** អង្គប្រជុំបានអនុម័តកំណត់ហេតុកិច្ចប្រជុំឧបសែលខមលើកទី ៨ និង ឧបសែលឡឹមលើកទី ៣ ។ អង្គប្រជុំក៏បានដឹងថាប្រហែលជាចាប់ពីខែកក្កដាទៅ ឧបសែលខម និងឧបសែលឡឹម ធ្វើការប្រជុំរាល់ខែតែមួយ ។

**ទី២.** អង្គប្រជុំបានទទួលព័ត៌មានអំពីខប់សែលដែលកំពុងត្រៀមលក្ខណៈប្រជុំខប់សែលប្រ៊េមនៅខេត្តកោះកុងនៅថ្ងៃទី៣ ខែកក្កដា។

**ទី៣.** អង្គប្រជុំបានទទួលព័ត៌មានអំពីកិច្ចការដែល គជប កំពុងតែរៀបចំជាពិសេសទាក់ទងនិងថវិការដើម្បីរៀបចំការបោះឆ្នោត ចំនួនប្រហែល ១៣.០៥០.០០០ ដុល្លា ។ សភាចាប់ផ្តើមជជែកពិភាក្សាអំពីវិសោធនកម្មច្បាប់បោះឆ្នោតចាប់ពីថ្ងៃនេះទៅ ។

**ទី៤.** បញ្ហាប័ណ្ណព័ត៌មានដែលចែកបានជាង ៦០ ភាគរយ លទ្ធផលបានល្អណាស់ ហើយផ្សព្វផ្សាយបញ្ហានេះឱ្យបានតទៅទៀត ទាក់ទងនិងចំនុចនេះ គជប នឹងជំរាបអំពីការិយាល័យបោះឆ្នោតដែលអាចនឹងឡើងទៅដល់ ១៩.៥០០ ដើម្បីបម្រើផ្តល់សេវាជូនដល់អ្នកបោះឆ្នោតដែលអាចកើនដល់ប្រហែល ៧ លាននាក់នៅឆ្នាំក្រោយនេះ ។ អង្គប្រជុំក៏បានជ្រាបអំពីការចុះឈ្មោះបោះឆ្នោតនៅមានបញ្ហាតំបន់ខ្លះ ជាពិសេសបញ្ហាអ្នកមកចុះឈ្មោះបោះឆ្នោតនៅតាមព្រំដែន ដោយសារចល័តច្រើនពេក បញ្ហាអាសយដ្ឋានក៏ពិបាកនិងត្រួតត្រា ប៉ុន្តែនឹងខំធ្វើយ៉ាងណាដើម្បីត្រួតត្រាឱ្យបានបន្តទៀតនៅក្នុងរឿងនេះ ។

**ទី៥.** អង្គប្រជុំបានស្តាប់របាយការណ៍របស់តំណាង ខុមហ្វ្រែល អំពីការអង្កេតមួយដែលនឹងធ្វើជាការចៃដន្យនៅ ១០ ខេត្តទៅលើការសាកសួរជាមួយនិងប្រជាពលរដ្ឋដែលបានចុះឈ្មោះរួចហើយចំនួន ៤២១ នាក់ ដើម្បីឱ្យដឹងថាតើបញ្ជីចុះឈ្មោះបោះឆ្នោតដែលក្រុមប្រឹក្សាឃុំសង្កាត់បានទទួលប្រតិភូកម្មអំណាចពី គជប មានគុណភាពអាចនិងទទួលយកបានយ៉ាងណា ។ លទ្ធផលបណ្តោះអាសន្នអាចនឹងជម្រាបជូនអង្គប្រជុំខ្លះនៅខែកញ្ញាឆ្នាំ ២០០៦ មុនការចុះឈ្មោះបោះឆ្នោត ឆ្នាំ ២០០៦ ។

**ទី៦.** អង្គប្រជុំបានពិភាក្សាទាក់ទងនឹងការចែកអំណោយ ។ សភាពការចែកអំណោយធំៗមានការវិវត្តទៅវិជ្ជមានច្រើន ហើយច្បាប់ក៏បានចងគ្រប់ទីកន្លែងទាំងអស់ ប៉ុន្តែអាចមិនមានបញ្ហាដោយសារការយោគយល់គ្នានៅពេលដែលមានការចែកអំណោយ ជាពិសេសពេលយុទ្ធនាការឃោសនាបោះឆ្នោត គឺតួអង្គគណបក្សនយោបាយដែលប្តឹងគ្នាទៅវិញទៅមក ជួនកាលខ្វះការយោគយល់គ្នានៅក្នុងសភាពចែកអំណោយតូចតាច ឬសមល្មមនៅឡើយនៅក្នុងរឿងនេះ។ ខប់សែល នឹងត្រូវការធ្វើការជាមួយគ្នាតទៅទៀតដើម្បីបង្កើនការយោគយល់ជាមួយគ្នាទៅវិញទៅមក ។

**ទី៧.** អង្គការខុមហ្វ្រែលបានជម្រាបជូនអង្គប្រជុំថានឹងមានធ្វើគម្រោងសាកល្បងមួយដើម្បីនឹងសង្កេត និងស្រាវជ្រាវព័ត៌មាន ស្តីពីការចាយរបស់គណបក្សនយោបាយថវិការបស់គណបក្សនយោបាយនៅក្នុងយន្តការនៃការបោះឆ្នោត ជាពិសេសនៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោត ។ ចំនុចនេះគ្រប់គ្នាទទួលស្គាល់ថានៅក្នុងបរិបទប្រទេសកម្ពុជាការត្រួតត្រារបស់ គជប របស់សង្គមស៊ីវិលទាំងមូលលើការចំណាយរបស់គណបក្សនយោបាយទាំងអស់ ដែលចូលរួមការបោះឆ្នោតនៅមានកម្រិតនៅឡើយ ហើយនៅមានរឿងជាច្រើនដែលត្រូវធ្វើការជាមួយគ្នាតទៅទៀត ។ បញ្ហាយុទ្ធនាការឃោសនាបោះឆ្នោតពីដំណាក់កាលបោះឆ្នោតមួយទៅមួយគឺផ្លាស់ប្តូរជានិច្ច និងភាគច្រើនការផ្លាស់ប្តូរពីអវិជ្ជមានទៅវិជ្ជមាន នេះក៏អាស្រ័យទៅលើបទពិសោធន៍កម្ពុជាបានឆ្លងកាត់ដោយខ្លួនឯងផ្ទាល់ ជាពិសេសបទពិសោធន៍ដែលឈានទៅរកភាពចាស់ទុំរបស់គណបក្សនយោបាយទាំងអស់ ជាពិសេសការយល់ដឹងរបស់ប្រជាពលរដ្ឋនៅក្នុងយន្តការនៃការបោះឆ្នោតលើទិដ្ឋភាពច្បាប់ និងនីតិវិធីនិងការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងយន្តការបោះឆ្នោតនេះ ។ អង្គប្រជុំបានទទួលស្គាល់ថាបញ្ហាប្រឈមនៅឡើយមានពីរធំៗគឺការចែកអំណោយដែលមានលក្ខណៈទ្រង់ទ្រាយធំ និងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងរដ្ឋ ទាំងឯកជន ។